# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ឈុន ផល K00894

## សម្ភាសន៍ជាមួយ ឈុន ផល អាយុ៤០ឆ្នាំ ភេទប្រុស

## មុខងារសម័យខ្មែរក្រហមៈ ប្រធានពួក

## រស់នៅភូមិថ្មី ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង

## សំភាសន៍ដោយៈ អ៊ីសា ឧស្មាន

## ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០២

## សរុបៈ ៤៥ទំព័រ

ឧស្មានៈ អត់ទោសលោកពូ លោកពូឈ្មោះអី សុំស្គាល់ឈ្មោះពូ?

ផលៈ ឈ្មោះឈុន ផល ។

ឧស្មានៈ អាយុប៉ុន្មានហើយពូ?

ផលៈ អាយុរាល់ថ្ងៃប៉ុន្មានទេច្រើនដែរ ។

ឧស្មានៈ ប៉ុន្មានហើយ?

ផលៈ ៤០ហើយ ប្រវត្តិឃុំគេដាក់ប៉ុន្មានទេ ។

ឧស្មានៈ បាទ! អត់អីទេ ។ ៤០ ភូមិនេះហៅភូមិអី?

ផលៈ ភូមិថ្មី ។

ឧស្មានៈ ឃុំ?

ផលៈ ឃុំចោងម៉ោង ។

ឧស្មានៈ ស្រុកទឹកផុស?

ផលៈ បាទ!

ឧស្មានៈ ខេត្តកំពង់ឆ្នាំង ។ ពូ! ប្រពន្ធលោកពូឈ្មោះអី?

ផលៈ ឈ្មោះកុង ។

ឧស្មានៈ ឈ្មោះកុង គាត់អាយុប៉ុន្មានហើយ?

ផលៈ អាយុគាត់ប៉ុន្មានទេ សួរគាត់គាត់មើល!

ប្រពន្ធៈ ៤៨ ។

ឧស្មានៈ ៤៨! ហើយកូនប៉ុន្មាននាក់ហើយ?

ផលៈ ៤ ។

ឧស្មានៈ កូន៤នាក់ កូនប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ផលៈ ប្រុស២, ស្រី២ ។

ឧស្មានៈ ចុះកូនបងគេអាយុប៉ុន្មាន?

ប្រពន្ធៈ ២២ហើយអាប្រុស ។

ឧស្មានៈ កូនបងគេអាយុ២២ហើយ?

ផលៈ បាទ!

ឧស្មានៈ ហើអស់កូនទៀតនៅ?

ផលៈ អស់ហើយ ។

ឧស្មានៈ អត់មានទៀតទេ?

ផលៈ អត់ទេ! មើលទៅបែបអស់ហើយ ។

ឧស្មានៈ សើច...

ផលៈ ប្រពន្ធវ័យចំណាស់បន្តិចហើយ ចាស់ហើយសន្មត់ថាអស់អីចឹងទៅ ថាម៉េចទេណ៎ ។

ឧស្មានៈ អត់ទេ! កូន៤ហ្នឹងល្មមដែរ ។

ផលៈ បាទ! ....

ឧស្មានៈ ប្រុស២, ស្រី២ ល្អហើយ ។

ផលៈ បាទ!

ដារ៉ាៈ ចុះបងហ៊ីនិងបងស្រីអ្នកណាបង?

ផលៈ គាត់បងខ្ញុំ ។

ឧស្មានៈ ការឆ្នាំណា?

ផលៈ ការ៧៩ ។

ឧស្មានៈ ពេលបែកមកវិញ ឬនៅជំនាន់ខ្មែរក្រហម?

ផលៈ អត់ទេ! បែកមកហើយ ចូលសម័យយើងរដ្ឋកម្ពុជា ។

ឧស្មានៈ បែកមក! គាត់ស្រុកកំណើតនៅឯណាដែរ?

ផលៈ ស្រុកកំណើតខ្ញុំនៅស្រុកឧត្តុង្គ ។

ឧស្មានៈ លោកពូឬ?

ផលៈ បាទ!

ខស្នានៈ នៅស្រុកខត្តុគ្គ?

ផលៈ បាទ!

ខស្នានៈ នៅឃុំអីដែរ?

ផលៈ ឃុំទេ ខ្ញុំមកតាំងពីតូចណុះ ។

ខស្នានៈ អូ! ហីប្រពន្ធស្រុកកំណើតនៅឯណា?

ផលៈ ស្រុកកំណើតគេនៅហ្នឹង ។

ខស្នានៈ ស្រុកនៅហ្នឹង?

ផលៈ បាទ! ខ្ញុំមកតាំងពីឆ្នាំយើង៦០ ខ្ញុំមកដល់ហ្នឹងបានមួយឆ្នាំរដ្ឋប្រហារ ។

ខស្នានៈ មកជាមួយឪពុកម្ដាយ តើឪពុកម្ដាយនៅទេ?

ផលៈ បាទ!

ខស្នានៈ ចុះឥឡូវគាត់នៅ?

ផលៈ នៅតែម្ដាយ ឪពុកខ្ញុំស្លាប់បាត់ហើយ ។

ខស្នានៈ ឥឡូវនៅម្ដាយ?

ផលៈ បាទ! នៅម្ដាយ ។

ខស្នានៈ ម្ដាយឈ្មោះអីហ្នឹង?

ផលៈ ឈ្មោះ វិន ។

ខស្នានៈ គាត់នៅឯណាឥឡូវ?

ផលៈ គាត់នៅទៅប្រខ្ចូតបាត់ហើយ គាត់ទៅលេងជាមួយកូនគាត់ឯណុះ គាត់មកនៅតែជាមួយខ្ញុំហ្នឹងដែរ ប៉ុនគាត់នៅហ្នុងបាត់ ។

ខស្នានៈ បាទ! ហីចុះឪពុកស្លាប់ពេលណា?

ផលៈ ឪពុកស្លាប់ឆ្នាំយើងមកពីអាដែងសម័យប៉ុល ពតឆ្នាំ៧៣ហ្នឹងដែរណា ។

ខស្នានៈ នៅក្នុងសម័យប៉ុល ពតហ្នឹង?

ផលៈ បាទ! នៅក្នុងសម័យប៉ុល ពតហ្នឹង ទៅចាញ់នៅឯតានីយើងអីលិច ចាញ់ឯតានី មកវិញគាត់ស្លាប់នៅហ្នឹងភូមិហ្នឹង ។

ខស្នានៈ ម៉េចបានទៅ...?

ផលៈ សម័យហ្នុងប៉ុល ពត ជម្លៀសទៅដែរ ។

ខស្នានៈ គាណីនៅឃុំ....?

ផលៈ   កាលហ្នឹងមិនមែនប៉ុល ពត ទេ ខ្មែរក្រហមណា ។

ឧស្មានៈ បាទ!

ផលៈ   ឲ្យឈ្មោះថាខ្មែរក្រហមឡើយទេ ជម្លៀសយកទៅណា មិនទាន់មានឈ្មោះប៉ុល ពត នៅឡើយទេ ជម្លៀសទៅហ្នឹងឆ្នាំយើង... ។

ឧស្មានៈ ៧៣ហ្នឹង! ពូទៅហ្នឹងដែរ ឬអត់ទេ?

ផលៈ   ទៅណា?

ឧស្មានៈ ទៅជាមួយឪពុកម្ដាយដែរ?

ផលៈ   ទៅ! ខ្ញុំនៅវត្ត ដល់ខ្ញុំនៅវត្តអីចឹងគេជម្លៀសឪពុកម្ដាយអស់លោកក៏ជម្លៀសដែរ ខ្ញុំត្រូវទៅរកម្ដាយទាន់នៅឯទ័ពតាឡាត់ឯណោះ ។

ឧស្មានៈ ស្រុកអី ទ័ពតាឡាត់ហ្នុង?

ផលៈ   ស្រុកអីទេ ភ្លេចបាត់ហើយ

ប្រពន្ធៈ មិនដែលស្គាល់ដែរ ។

ផលៈ   ឃុំជៀប ។

ឧស្មានៈ ឃុំជៀប ស្រុកអី?

ផលៈ   ស្រុក១៨ហ្នឹងដែរ ។

ឧស្មានៈ អូ!

ផលៈ   ស្រុក១៨ជាមួយហ្នឹង ប៉ុន្ដែឃុំជៀប ។

ឧស្មានៈ ស្រុក១៨ ស្រុកទឹកផុសហ្នឹងដែរ?

ផលៈ   បាទ! ស្រុក១៨ជាមួយគ្នា ។

ឧស្មានៈ ឪពុកឈ្មោះអី?

ផលៈ   ឪពុកខ្ញុំ?

ឧស្មានៈ បាទ!

ផលៈ   ឈ្មោះភួង ។

ឧស្មានៈ ពេលដែលជម្លៀសទៅ លោកពូនិយាយម៉េចថាលោកពូនៅវត្ត?

ផលៈ   បាទ! ខ្ញុំនៅវត្ត ។

ឧស្មានៈ ធ្វើអីនៅវត្តហ្នុង?

ផលៈ   ទៅរៀន រៀនប្រុងយើងថាបួសហ្នឹងណា ។

ខស្មានៈ បួសហើយនៅ?

ផលៈ នៅ! អត់ទាន់បានបួសនឹងគេទេ យើងនៅតូចណា ។

ខស្មានៈ ពូនៅវត្តតាំងពីឆ្នាំណាមក?

ផលៈ ខ្ញុំនៅវត្តពីឆ្នាំ៧០ ឆ្នាំដែលយើងរដ្ឋប្រហារហ្នឹងណា ។ ខ្ញុំមកឆ្នាំ៦០ ឆ្នាំ៧០ខ្ញុំចូលនៅវត្ត ដល់ឆ្នាំ៧៣ជម្លៀសទៅលិច ៧៤មកវិញ ។

ខស្មានៈ វត្តហ្នុង វត្តណាពូ?

ផលៈ វត្តសំប៉ានយើងហ្នឹង ។

ខស្មានៈ វត្តណា?

ផលៈ វត្តសំប៉ានស្គាល់ទេ?

ខស្មានៈ វត្តសំប៉ាន! នៅក្នុងភូមិនេះដែរ?

ផលៈ នៅហ្នឹង វត្តនៅខាងកើត ។

ខស្មានៈ អូ! ហើពេលលោកពូនៅវត្តហ្នុងឪពុកម្តាយពូគេជម្លៀស?

ផលៈ បាទ!

ខស្មានៈ ចុះអ្នកភូមិផ្សេងៗទៀតនោះ?

ផលៈ ជម្លៀសទាំងអស់ ។

ខស្មានៈ មូលហេតុអីបានជម្លៀសអីចឹង?

ផលៈ មូលហេតុដូចទាហានយើងនៅនេះ ទាហាននៅរមាសហ្នឹងគេជម្លៀសឲ្យដកទៅម៉ាផ្នែក ឲ្យដកទៅនៅឯលិចណា ឲ្យផុតពីជិតទាហាន ខ្មែរក្រហមគេកៀយកទៅដាក់ឯហ្នុងប្រក់ បើយហ្នុង ទ័ពតាឡាតហ្នុងណា ។

ខស្មានៈ ឲ្យជិតទាហានម៉េច អត់ទោស អត់ទាន់យល់?

ផលៈ ទាហានកាលសម័យលន់ នល់ យើងនេះណា ក្រែងគាត់ចង់សួរថាអីចឹងប្តុ?

ខស្មានៈ បាទ! ខ្ញុំចង់សួរថាម៉េចបានជម្លៀសហ្នឹងណា?

ផលៈ ហ្នឹងជម្លៀសហ្នឹង កាលហ្នុងខ្មែរក្រហមមិនមានការគៀបសង្កត់នៅលើប្រជាជនខាងក្រៅ ខាងណុះមិនខាងក្នុង ។

ខស្មានៈ ខាងណា ខាងជម្លៀសទៅហ្នឹង?

ផលៈ បាទ! ខាងលន់ នល់ មិនគេខាងក្នុង ខាងទ័ពខ្មែរក្រហមមិនខាងក្រៅ!

ខស្មានៈ បាទ!

ផលៈ   យើងនៅតំបន់ខាងខ្មែរក្រហម  ហើយខ្មែរក្រហមត្រូវជម្លៀសយកទៅ?

ឧស្មានៈ ចុះបើអត់ជម្លៀសយ៉ាងម៉េចដែរ?

ផលៈ   អត់ជម្លៀសដឹងយ៉ាងម៉េច  បើគេជម្លៀសទៅត្រូវតែទៅហ្នឹងគេ  សើច...  យើងត្រូវតែទៅនឹងគេ  ពិបាកគេចគ្រាប់ផ្លោង  ហីនៅក្នុងតំបន់គេត្រូវតែកៀរយកទៅ ។

ប្រពន្ធៈ អីណុះចង់បានយកទៅឯណុះ  អីណេះចង់បានយកមកឯណេះ ។

ឧស្មានៈ ហីលោកពូពេលហ្នុង  ពេលដែលគេជម្លៀសហ្នុង  ពូបានចេញពីវត្តមកហើយ?

ផលៈ   បាទ!  ចេញពីវត្តមកតាមម៉ែឪក្រោយគេទេ  បានសួរដំណឹងទៅទាន់គាត់នៅទំពតាឡាត់ណុះ ។

ឧស្មានៈ ហើយពូនៅណុះរយៈពេលប៉ុន្មានបានមកវិញ?

ផលៈ   មួយឆ្នាំហ្នុងទៅហ្នឹងទាំងអស់ហ្នឹងទាំងភូមិទាំងអីហ្នឹង  ប៉ុនវាទៅផ្ដើមអត់ទាន់បានគ្នាណាវាបែកគ្នាគេនៅដោយគ្រួសារគេ  ខ្ញុំនៅដោយគ្រួសារខ្ញុំណា  ប៉ុនដូចខ្ញុំបានជំរាបខាងដើមមក៧៩បានរៀបការ  ៧៩រំដោះបានហើយវានៅ...ទទួលមានអាវក្រហមផងហីសាធារណរដ្ឋប្រជាមានិតផងក្នុងពេលខែហ្នុងខ្ញុំរៀបការ  តំបន់នៅប្រទាញប្រទង់ណា ។

ឧស្មានៈ ហីលោកពូពេលត្រឡប់មកពីទំពតាឡាត់ហ្នុងវិញនៅឆ្នាំណា?

ផលៈ   នៅឆ្នាំ៧៨ ។

ឧស្មានៈ ហីពូត្រឡប់មកវិញនៅឯណាទៅ?

ផលៈ   ត្រឡប់មកវិញនៅហ្នឹងដដែល ។

ឧស្មានៈ នៅតាមភូមិហ្នឹង  នៅតាមផ្ទះខ្លួនឯងដែរ ។

ផលៈ   បាទ!  នៅក្នុងសហករណ៍ហ្នឹង  សហករណ៍ភូមិថ្មីហ្នឹងដដែល  វាមិនទាន់ដល់អាយើងហៅថា  មិនទាន់ដល់សហករណ៍  ក្រុមសាមគ្គីម៉ារាជហ្នុងនោះ  ក្រុមសាមគ្គីទេ ។

ឧស្មានៈ ហីលោកនៅជាមួយឪពុកម្ដាយឬក៏យ៉ាងម៉េច?

ផលៈ   នៅជាមួយឪពុកម្ដាយទេ ។

ឧស្មានៈ ហីបន្ទាប់មកទៀត?

ផលៈ   នៅជាមួយឪពុកម្ដាយរៀនសាលាដដែល  រៀនសាលាសម័យប៉ុល  ពតយើងនេះ ។

ឧស្មានៈ នៅវត្ត?

ផលៈ   អត់ទេ!  រៀននៅក្នុងក្រុមសាមគ្គី  តែរៀនក្នុងសាលាសម័យក្រុមសាមគ្គីហ្នឹងដែររៀននៅទួលចំប៉ី ។

ខស្នានៈ ហើចុះវត្តនៅមានសាលាទៀតទេ?

ផលៈ វត្តអត់មានទេចប់ហើយ ។

ខស្នានៈ មានលោកសង្ឃអី?

ផលៈ លោកសង្ឃក៏អត់ដែរពេលនោះអត់មានទេ ។ លោកគេជម្លៀសយកទៅតានីណុះ បងខ្ញុំស្រគត់អស់មួយអន្ត កាលម៉ាជំនាន់ជម្លៀសហ្នឹងគាត់សុគត់បាត់ទៅ ។

ខស្នានៈ ហើលោកពូរៀនបានប៉ុន្មានឆ្នាំ រៀននៅសាលាខ្មែរក្រហមហ្នឹង?

ផលៈ ខ្ញុំរៀនបានអត់ដល់មួយឆ្នាំផងទេ ។

ខស្នានៈ អត់ដល់មួយឆ្នាំទេ?

ផលៈ បាទ!

ខស្នានៈ ហើយាំងម៉េចទៀតទៅ?

ផលៈ ក្រោយរយៈពេលក្រោយមក ក៏ខ្ញុំនិយាយថាសអីចឹងទៅចុះ រយៈក្រោយមកខ្ញុំក៏គេចាត់តាំងឲ្យទៅនៅអីឯណាក៏ខ្ញុំអត់ទាន់បានដឹងដែរណា ប៉ុន្តែគេថា គេឲ្យទៅ ហ្នឹងចូលដល់ដំណាក់សម័យយើងហើយណា សម័យប៉ុល ពតហ្នឹង ។

ខស្នានៈ អាហ្នឹងឆ្នាំណា?

ផលៈ នៅឆ្នាំ៧៥ ។

ខស្នានៈ ឆ្នាំ៧៥ ខែណា?

ផលៈ ខែអត់បានដឹង ។

ខស្នានៈ មុនរំដោះ ឬក៏ក្រោយរំដោះ ខ្មែរក្រហមរំដោះភ្នំពេញណា?

ផលៈ ខ្មែរក្រហមរំដោះបានហើយ ទើបគេស្រាវជ្រាវខ្ញុំហ្នឹងឲ្យទៅ មិនដឹងគេឲ្យទៅកន្លែងណាទេ អត់ទាន់ទៀង ។

ខស្នានៈ ឲ្យចេញពីសាលា?

ផលៈ ចេញពីសាលាហ្នឹងទៅហ្នុង ។

ខស្នានៈ កាលហ្នុងលោកពូអាយុប៉ុន្មានហើយ?

ផលៈ អាយុខ្ញុំកាលហ្នុងវាក្បែរ ១២អីហ្នឹង ប៉ុណ្ណឹង ខ្ញុំនៅក្មេងមែនទែន ។

ខស្នានៈ ហើពីណាដែលយកលោកពូទៅហ្នឹងណា ចេញពីសាលាទៅហ្នឹងណា?

ផលៈ យកទៅហ្នឹងក្មេចអស់ហើយ យកទៅហ្នឹងគេជូន គេអ្នកមកពីចម្ងាយៗ គេមកយកគេមកទទួលម៉ង គេជូនទៅម៉ងអត់បានស្គាល់គេទេ គេជូនទៅលើរមាសយើងនេះណា ។

ខស្នានៈ ហើគេយកទៅទាំងសិស្សសាលាហ្នឹងគេយកទៅទាំងអស់គ្នា ឬក៏យកភាគខ្លះ?

ផលៈ អត់ទេ! គេថាក្នុងមាឃុំគេរើសតែម្នាក់អីចឹងម៉ង ។

ខស្នានៈ ក្នុងមាឃុំ?

ផលៈ បាទ!

ខស្នានៈ ហើលោកពូដូចថាមានគុណសម្បត្តិយ៉ាងម៉េចបានដែលរើសយកលោកពូណា តែម្នាក់ហ្នឹង?

ផលៈ អត់មានគុណសម្បត្តិអីទេ មារាជហ្នុងនោះ ព្រោះគ្មានគុណសម្បត្តិអីឲ្យធំដុំទេ គេរើសត្រង់ថាវណ្ណៈកម្មករ កសិករ វណ្ណៈក្រខ្សត់អីចឹងទៅណា អានេះសម័យប៉ុល ពតគេយកអីចឹង បានគេបញ្ជូនខ្ញុំ ខ្ញុំប្រកែកថាអត់ទៅដែរទេ ប៉ុន្តែអត់ទេមានឈ្មោះឯងហ្នឹងហើយ ត្រូវតែទៅអីចេះ ។

ខស្នានៈ ហើចិត្តលោកពូចង់ទៅទេ?

ផលៈ អត់ចង់ទេ!

ខស្នានៈ ចុះឪពុកម្តាយ?

ផលៈ ឪពុកម្តាយក៏អត់ហ៊ានហាមឃាត់ដែរាជនោះ អាណាហ៊ានហាមឃាត់អត់មានទេ កូនគេថាកូនអង្គការម៉េចនោះ ស្រេចគេចាត់តាំង ចាត់តាំងផ្លូវណា គឺដើរផ្លូវហ្នុង ។

ខស្នានៈ ហើគេយកលោកពូទៅណាទៅលោកពូ?

ផលៈ យកទៅ! ពីហ្នឹងទៅខ្ញុំនៅសាលាលេខ៩ ។

ខស្នានៈ ពេលដែលពូចេញពីភូមិទៅសាលាលេខ៩ហ្នុង ប្រហែលជាក្រោយគេវៃយកភ្នំពេញរយៈពេលប៉ុន្មាន?

ផលៈ យូដែរ! ប្រហែលជាមួយខែអីដែរមើលទៅ ។

ខស្នានៈ ប្រហែលជាមួយខែទេ?

ផលៈ បាទ! យកតំបន់សាលាលេខ៩យើងរំដោះរួចហើយណា សម័យប៉ុល ពតគេកាន់កាប់គេរំដោះបាន គេដាក់កម្លាំងគេហ្នុង ។

ខស្នានៈ បាទ! ហើយឲ្យធ្វើអីនៅសាលាលេខ៩?

ផលៈ សាលាលេខ៩ នៅហ្នុងជាកុមារសំណាក់ទេ សំណាក់ប៉ុនធ្វើពលកម្ម យើងជីរាស់ដីក្នុងចម្ការ បន្ទាយទាហានយើងដាំជាបន្លែបន្ទុកទៅណាស់ ។

ខស្នានៈ ដាំបន្លែ?

ផល: បាទ! ដាំបន្លែហ្នឹងណា យើងជាកុមារទៅដល់សំណាក់នៅកន្លែងហ្នឹងត្រូវធ្វើពលកម្ម យើងនៅកន្លែងណា ត្រូវធ្វើពលកម្មកន្លែងហ្នុងហើយអីចេះ ។

ឧស្មាន: ហើយបន្ទាប់មកទៀតទៅ?

ផល: បន្ទាប់មកទៀតគេបញ្ជូនមកទៀតហើយ ។

ឧស្មាន: បញ្ជូនទៅណា?

ផល: ខ្ញុំនៅហ្នុងប្រហែលមួយអាទិត្យ ។

ឧស្មាន: នៅកន្លែងសាលាលេខ៥ហ្នឹង?

ផល: បាទ! បានគេមកយកទៀត ខ្ញុំនិយាយទៅអត់ស្គាល់ទាំងអស់ រឿងអ្នកដឹកនាំហ្នុងខ្ញុំស្គាល់តិច ព្រោះគេមកយកៗទៅតាមតែគេណា ដឹងឈ្មោះអីគេមកយក...

ឧស្មាន: ក្មេងៗនៅសាលាលេខ៥ហ្នឹងប៉ុន្មាននាក់ទៅ ដែលប្រជុំគ្នានៅហ្នុង?

ផល: តាមខ្ញុំប៉ាន់ស្មានមើលមិនបានរាប់ទេប្រហែលជា២០០ ។

ឧស្មាន: ក្មេងៗហ្នឹងមកពីណាខ្លះ?

ផល: ក្មេងៗហ្នុងទៅគ្រប់ឃុំ ដូចខ្ញុំបានជំរាបខាងដើមថាគេជ្រើសរើសអីចឹងណា ម៉ាឃុំមួយម៉ាភូមិមួយអីចឹងទៅណា តាមភូមិមួយ ម៉ាខេត្តមួយអីចឹងទៅ គេយកទៅប្រជុំគ្នាដាក់ណុះ ។

ឧស្មាន: កន្លែងហ្នុងជាស្អីទៅបានគេយកក្មេងៗទៅប្រមូលផ្តុំនៅហ្នុង?

ផល: ខ្ញុំអត់ដឹងដែរ ។

ឧស្មាន: ឃើញក្មេងដែលនៅហ្នុងពីអាយុប៉ុន្មានដល់អាយុប៉ុន្មាន ចាស់ជាងគេអាយុប៉ុន្មានធំជាងគេណា?

ផល: ធំជាងគេអស់ហើយត្រឹម១៦-១៧ ។

សុជា: ក្មេងបំផុតត្រឹមអាយុប៉ុន្មាន?

ផល: ក្មេងបំផុតត្រឹម១៥ ។

សុជា: អីចឹងកាលហ្នុងពូអាយុប៉ុន្មានដែរ?

ផល: ខ្ញុំកាលហ្នុងទៅវា១២ ទៅពីហ្នឹងទៅណា ។

សុជា: អីចឹងពូក្មេងជាងគេក្នុងចំណោម?

ផល: ក្មេង! អត់ទេមានគេក្មេងជាងខ្ញុំទៅទៀតក៏មិនដឹង សើច... ។

សុជា: អ្នកគ្រប់គ្រងកន្លែងកុមារហ្នុងឈ្មោះអីគេបង?

ផលៈ    កន្លែងគ្រប់គ្រងកុមារដែលបញ្ជូនហ្នឹង?

សុជាៈ  បាទ!

ផលៈ    អត់បានស្គាល់គេដែរ គ្រាន់តែទៅរួមរស់ជាមួយគ្នាហ្នឹង មិនបានស្គាល់គេទេណា ។

សុជាៈ  បាទ!

ផលៈ    យើងនៅត្រឹមតែមួយអាទិត្យទេណា អត់បានស្គាល់គេទេ ។

សុជាៈ  ចុះពូមានស្គាល់អ្នកផ្សេងទៀតដែលនៅជាមួយពូហ្នឹងទេ?

ផលៈ    អ្នកស្គាល់ ។

សុជាៈ  ឈ្មោះអី?

ផលៈ    អ្នកស្គាល់ទៅហ្នឹងក៏អត់សូវស្គាល់គេ ស្គាល់តែគ្នាឯងទៅពីហ្នឹងទៅ៣នាក់អី ។

សុជាៈ  ឈ្មោះអីគេខ្លះ ។

ផលៈ    ទៅពីឃុំហ្នឹងបានគ្នាតែ៣នាក់ទៀត ៤នាក់ទាំងខ្ញុំ ។

សុជាៈ  ឈ្មោះអីខ្លះពូ?

ផលៈ    ឈ្មោះមួយ ឈ្មោះយ៉ាង នៅដូនម៉ៅនេះ មួយសែបក៏នៅដូនម៉ៅដែរ មួយរ៉ាត់ នៅត្រពាំងជុំយើងនេះណា អូនៅរលាំងកែង វត្តរលាំងកែងណា ។

ឧស្មានៈ សព្វថ្ងៃនៅទេ?

ផលៈ    បាត់អស់រលីង អត់មានជួបមួយ ។

សុជាៈ  ហើពួកគាត់ហ្នុងបានទៅដល់ភ្នំពេញជាមួយពូដែរ ឬអត់ទេ?

ផលៈ    បាន! បានដូចគ្នា ។

ឧស្មានៈ ហើបន្ទាប់ពីហ្នុងទៀត ទៅណា?

ផលៈ    ខ្ញុំមកនៅបឹងទំពុន ។

ឧស្មានៈ នៅបឹងទំពុន?

ផលៈ    បាទ!

ឧស្មានៈ រយៈពេលប៉ុន្មាន?

ផលៈ    កន្លះខែ ។

ឧស្មានៈ គេឲ្យធ្វើអីនៅបឹងទំពុនហ្នុង?

ផលៈ    នៅហ្នុងដាំបន្លែ ហើដូចថាធ្វើការងារពលកម្មប្រចាំបន្តិចបន្តួចណា អានេះកុមារដូចថាយកទៅដាក់ដីងគេឲ្យធ្វើស្អីៗ ចេះតែថានៅហ្នុងទៅ ។

ឧស្មានៈ ចុះក្មេងៗហ្នុងចេញពីសាលាលេខហ្នុងទៅធ្វើដំណើរដោយស្អីខ្លះ ជិះស្អីទៅ?

ផលៈ ជិះឡាន ។

ឧស្មានៈ ពីណាមកយកហ្នុង?

ផលៈ អត់ដឹងពីណា ឃើញតែឡាន់គេដំរៀបហ្នុង គេហៅឈ្មោះឲ្យឡើង ឡើងនឹងគេទៅ ។

ឧស្មានៈ ហីគេយកទៅទាំងអស់ប្អុអត់ទេ?

ផលៈ យកទាំងអស់អស់ ។

ឧស្មានៈ នៅបឹងទំពុនហ្នុងបន្ទាប់មកទៀតយ៉ាងម៉េចទៀត?

ផលៈ បន្ទាប់មកទៀតនៅហ្នឹងបានកន្លះខែ ។

ឧស្មានៈ ហីទៅឯណាទៀត?

ផលៈ គេបញ្ជូនទៅចូលសាលាយោធា៧០៣ ។

ឧស្មានៈ បឹងទំពុនកន្លះខែ?

ផលៈ បាទ!

ឧស្មានៈ ហីបន្ទាប់មកទៅសាលា...

ផលៈ សាលាយោធា៧០៣ ហើយបានសម័យហ្នុងគេដាក់... ។

ឧស្មានៈ នៅឯណាសាលាយោធា៧០៣ហ្នុង?

ផលៈ នៅខាងណាតាខ្មៅទេ ស្ពានយើងឆ្លងមួយហ្នឹង ។

ឧស្មានៈ ក្បែៗតាខ្មៅហ្នឹងដែរ?

ផលៈ បាទ! ក្បែរតាខ្មៅគ្រាន់តែឆ្លងព្រែកមួយហ្នឹង ។

ឧស្មានៈ គេធ្វើអីនៅហ្នុង?

ផលៈ នៅហ្នុងគេរៀន គេរៀនពីរឿងច្បាប់ទ័ព ។

ឧស្មានៈ ពីណាបង្រៀនហ្នឹង?

ផលៈ ច្បាប់នៅកន្លែងហ្នុងខ្ញុំភ្លេចអស់បាត់ទៅហើយ ប៉ុន្តែកន្លែងហ្នុងពីដើមមកគេថាមាន ឈ្មោះទុយ ឈ្មោះអីអីចឹងទៅណា ប្រធានគេធំៗណា ប៉ុន្តែក្រោយៗមកទៀត ខ្ញុំភ្លេចអស់ហើយអត់បានស្គាល់គេ អត់បានចាំទេណា ។

ឧស្មានៈ ហីរៀនរយៈពេលប៉ុន្មាន?

ផលៈ រៀនហ្នុងបែបជា៦ខែជាង ។

ឧស្មានៈ ៦ខែជាង ហីបន្ទាប់មកទៀត?

ផលៈ ៦ខែជាង គេបិទវគ្គអីចឹងទៅ គេបានប្រជុំកុមារហ្នឹងណា កុមារដែលខ្ញុំទៅរៀនហ្នឹងណា គេហៅប្រជុំអីចឹងទៅ ដល់គេថាអ្នកដែលរៀនចប់បិទវគ្គហើយគេឲ្យមកស្រុក មកភូមិវិញ ។

ខស្នានៈ ពីណាប្រាប់អីចឹង?

ផលៈ គេអ្នកប្រជុំកន្លែងសាលាហ្នុងណា ។

ខស្នានៈ ឈ្មោះអី?

ផលៈ ដឹងឈ្មោះអីទេ បើគ្នាគេគគោគ គជី ដូចថាខ្ញុំវាភ្លេចអស់ដែរទៅហើយ ។

ខស្នានៈ ចុះអាពេលសាលាបិទវគ្គសាលាហ្នុងនៅក្នុងឆ្នាំ៧៥នៅឡើយ ឬក៏ចូលឆ្នាំ៧៦ហើយ?

ផលៈ ចូល៧៦ហើយ ។

ខស្នានៈ នៅខែណាដែរ?

ផលៈ អត់បានចាំ ព្រោះអត់បានចាំទេ ដូចអត់មានគិតអត់មានអីទេយេិងកូនចៅគេណា...

ខស្នានៈ ដើមឆ្នាំ ឬក៏ចុងឆ្នាំ ៧៦ហ្នុង?

ផលៈ ៧៦បែប ទំនងបែបចុងហើយ បើមិនចុង ហ្ហេ! បែបដើមទេ បើមិនដើមពាក់កណ្តាល ប៉ុណ្ណឹង ខ្ញុំអត់បានចាំទេណា ព្រោះថាចាំឯណាបើវាយូដែលឆ្នាំហើយហ្នឹង ខ្ញុំកាលហ្នុងក៏វានៅក្មេងដែរ ។

ខស្នានៈ រួចហើយបន្ទាប់មកទៀតទៅ?

ផលៈ បន្ទាប់មកទៀតគេបានប្រជុំអីចឹងទៅ គេប្រជុំថាអ្នកណារៀនចប់ហើយ គេឲ្យមកស្រុកមកភូមិវិញក៏នាំគ្នាអរទៅណា នាំគ្នាអរដល់បញ្ជូនៗទៅត្បូង បញ្ជូនទៅនៅឯព្រែកហូរ បញ្ជូនទៅហ្នឹងវាចេះ... ។

ខស្នានៈ បញ្ជូនទៅទាំងអស់គ្នានៅហ្នុង?

ផលៈ អត់ទេបែកគ្នា! បែកគ្នាត្រឹមហ្នុងហើយ ខ្លះក៏បែកទៅអង្គភាពផ្សេង ខ្លះក៏បែកផ្សេងចែកគ្នាគ្រប់ផ្នែក ។

ខស្នានៈ ហើលោកត្រូវទៅកន្លែងព្រែកហូរហ្នឹង?

ផលៈ បាទ! ហ្នឹងអាពួកទៅពីហ្នឹងប៉ុន្មាននាក់ទាំងអស់គ្នាក៏បែកគ្នាបាត់តាំងពីថ្ងៃហ្នុងមករហូតពួកដែលនៅហ្នឹងណា ពួកដែលទៅ ដែលស្គាល់គ្នា៣-៤នាក់ហ្នឹង បាត់រហូតអត់ដែលមានជួបគ្នាទេ រហូតដល់រត់មកដល់រាល់ថ្ងៃទៀត ។

ខស្នានៈ ហើយលោកពូគេឲ្យទៅនៅធ្វើអីព្រែកហូរហ្នុង?

ផលៈ   នៅឯណុះធ្វើស្រែប្រាំង  ធ្វើស្រែប្រាំងធាក់រហាត់ធាក់អី  ដាក់ទឹកជាមួយកងនារីកងអី គេហ្នុងណា ដេញចាបដេញអីអីចឹងទៅណា ។

ខស្នានៈ ហើយក្មេងប៉ុន្មានទៅដែលយកទៅព្រែកហូរហ្នុង?

ផលៈ   អត់បានចាំទេ! ២, ៣ក្រុមណុះ វាច្រើនដែរ ។

ខស្នានៈ អត់ដឹងចំនួនទេ?

ផលៈ   អត់ដឹងចំនួនទេ ។

ខស្នានៈ ពីណាប្រធាននៅព្រែកហូរហ្នុង?

ផលៈ   អត់បានចាំទេ និយាយទៅអត់បានចាំម៉ង រឿងចាំ ចាំតិច ។

ខស្នានៈ ហើគេឲ្យពូធ្វើកិច្ចការអីខ្លះនៅព្រែកហូរហ្នឹង?

ផលៈ   នៅហ្នុងដូចខ្ញុំថាអីចឹង ដូនកាលដើររកកណ្តុរស៊ីស្រែប្រាំងអីចឹងទៅ ហើម្យ៉ាងទៀតធាក់ទឹករហាត់អីចឹងទៅ ហើយដេញចាបអីចឹងទៅតែអីប៉ុណ្ណឹងទេដែនការគេ… ។

ខស្នានៈ បងនៅព្រែកហូរហ្នុងគេហៅអង្គភាពអីដែរ?

ផលៈ   អង្គភាពកុមារ ។

ខស្នានៈ កុមារហ្នឹងមានឈ្មោះទេ?

ផលៈ   គេហៅកុមារឈានមុខ  ប៉ុនកុមារហ្នឹង…ធ្វើស្រែនៅឡើយទេ  ប៉ុនគេឲ្យឈ្មោះថាកុមារឈានមុខ ។

ខស្នានៈ ហើយបន្ទាប់មកទៀតពូ?

ផលៈ   បន្ទាប់មកទៀតគេបញ្ជូនមកនៅដល់ដំណាក់កាលបញ្ជូនមកនៅព្រៃសរ  ព្រៃសរមកត្បូងពោធិ៍ចិនតុង ខាងណាទេខ្ញុំភ្លេចអស់… ។

ខស្នានៈ អីចឹងពូនៅព្រែកហូររយៈពេលប៉ុន្មានបានមកនៅព្រៃសរ?

ផលៈ   អត់បានចាំ អត់បានចាំអាកំណត់ថាយើងនៅៗអីអត់បានចាំណា ។

ខស្នានៈ ហើយមកព្រៃសរប្រហែលជាខែណា ឆ្នាំណា?

ផលៈ   អត់បានចាំភ្លេចអស់រលីង អត់បានចាំអារឿងខែ អារឿងថ្ងៃហ្នឹងណា ។

ខស្នានៈ នៅព្រៃសរហ្នុងយកមកទាំងអស់គ្នា ឬអត់ទេ?

ផលៈ   យកមកទាំងអស់គ្នាកុមារហ្នឹង ។

ខស្នានៈ នៅទាំងអស់គ្នាដែលកុមារបញ្ជូនទៅព្រែកហូរហ្នឹងហើយ  បកមកព្រៃសរទាំងអស់គ្នាហ្នឹង?

ផល: បាទ! ទាំងអស់គ្នា ។

ខស្នានៈ ហើបន្ទាប់មកទៀតនៅព្រៃសរហ្នឹងឲ្យធ្វើអី?

ផល: នៅព្រៃសរហ្នឹងក៏ធ្វើស្រែដែរអាហ្នឹងណា នៅព្រៃសរធ្វើស្រែហ្នឹងមានអ្នកកាន់ក្តាប់ហ្នឹងជាអ្នកពិការទៀត ។

ខស្នានៈ ឈ្មោះអី?

ផល: ឈ្មោះចយ ។

ខស្នានៈ ចយហ្នឹងជាប្រធានស្អីទៅ?

ផល: ប្រធានកុមារ ប៉ុនអ្នកពិការ ពីការអីចឹងទៅ គាត់ពិការគាត់ខ្វិន គាត់គ្រាន់តែម៉ាដើរបាន គ្រាន់ម៉ាដឹកនាំកុមារទៅណា គ្រាន់តែប៉ុណ្ណឹងទេ ។

ខស្នានៈ ហើចុះលើចយទៀតមានឈ្មោះអី?

ផល: លើទៀតអត់បានដឹង ។

ខស្នានៈ មេធំជាងគេណា?

ផល: អើហ្នឹងអត់ដឹង ។

ខស្នានៈ គេឲ្យធ្វើអីទៅនៅព្រៃសរ?

ផល: នៅព្រៃសរដូចខ្ញុំថាអីចឹងធ្វើស្រែ ដកស្ទូងជាមួយកងនារីខ្លះអីចឹងទៅ គាត់អ្នកដឹកនាំកុមារគាត់ពិការហ្នឹងចេះតែដឹកនាំកុមារហ្នឹងទៅណា ។

ខស្នានៈ ព្រៃសរហ្នឹងមានឈ្មោះទៀត ជាមន្ទីរ ឬក៏អង្គភាពគេដាក់យ៉ាងម៉េច ឈ្មោះកន្លែងហ្នឹងណា?

ផល: បាទ! មណ្ឌលកុមារដដែល កន្លែងហ្នុងអត់ដឹងថាមន្ទីរថាម៉េចអត់ដែល អត់មានឈ្មោះផង អត់មានទេគ្រាន់តែកងកុមារដដែល ខ្ញុំទៅនៅនឹងណាដែលខ្ញុំឈានជើងទៅនៅកុមារ ដដែល នៅកងកុមារដដែល ប៉ុនមិនដឹងកន្លែងហ្នុងគេដាក់ឈ្មោះថាម៉េច គេថាបញ្ជូនមកដល់កន្លែង ដល់កន្លែងព្រៃសរ គ្រាន់តែប្រាប់ប៉ុណ្ណឹង ឲ្យខ្ញុំថាកន្លែងហ្នុងមានឈ្មោះថាម៉េចក៏ខ្ញុំអត់ហានថាដែរណា ព្រោះឃើញមន្ទីរអី ក៏មិនទាន់ដឹងថាមន្ទីរអីដែរ ។

ខស្នានៈ ពូនៅរយៈពេលប៉ុន្មាននៅព្រៃសរហ្នុង?

ផល: ទេ! នៅដូចតិចដែលទេ ។

ខស្នានៈ ប្រហែលប៉ុន្មានខែដែរ?

ផល: ប្រហែលជាមួយខែកន្លះ ពីរខែអីប៉ុណ្ណឹងទេមើលទៅ ។

ខស្មានៈ ហើយបន្ទាប់មកទៀតទៅ?

ផលៈ បន្ទាប់មកគេបញ្ជូន ។

ខស្មានៈ បញ្ជូនមក...?

ផលៈ គេយកកុមារគេបញ្ជូនមកទៀត ។

ខស្មានៈ ដកទាំងអស់ឬអត់?

ផលៈ ដល់តែពេលហ្នឹងរបៀតរប៉ុយហើយ បាត់ពាក់កណ្ដាល នៅពាក់កណ្ដាល ឃើញពាក់កណ្ដាល កាន់តែបាត់អស់ទៅ ។

ខស្មានៈ បាត់ទៅណាដែរ?

ផលៈ បាត់មិនដឹងទៅខាងណា ចេះតែបែកគ្នាបន្តបន្ទាប់ មកម៉ាដំណាក់ឃើញចំនួនថា១០០ ដល់មកលើកក្រោយទៀតឃើញតែ៥០ មកលើក្រោយទៀតឃើញតែ២០អីចឹងទៅណា ចេះតែបែកគ្នាអស់ដឹងគេចាត់តាំងទៅខាងណាវាអីចឹងណា ។

ខស្មានៈ ហើលោកពូត្រូវគេចាត់តាំងទៅណាទៀត?

ផលៈ ចាត់តាំងមកភ្នំពេញ ។

ខស្មានៈ ចាត់តាំងមកនៅភ្នំពេញឬ?

ផលៈ បាទ!

ខស្មានៈ នៅកន្លែងណា?

ផលៈ នៅកន្លែងយើងមន្ទីរ... ។

ខស្មានៈ មន្ទីរហ្នឹងឈ្មោះមន្ទីរអីកាលជំនាន់ហ្នឹង?

ផលៈ មន្ទីរស-២១ នឹងឈានមកដល់ហើយ ដំណាក់កាលដែលខ្ញុំដើរណា ខ្ញុំរាយរ៉ាប់ប្រាប់ទាំងអស់មកហើយ ។

ខស្មានៈ ហើមកនៅមន្ទីរស-២១ឆ្នាំណាទៅ?

ផលៈ ឆ្នាំដូចមិនសូវបានចាំទេ ។

ខស្មានៈ ហើយពីណាបញ្ជូនមកហ្នឹង?

ផលៈ កន្លែងកងកុមារគេហ្នឹងគេបញ្ជូនមក ប៉ុនដឹងឈ្មោះណាគេបញ្ជូន បើគ្រាន់តែគេថា គេឲ្យមកណា ។

ខស្មានៈ ហើមកប៉ុន្មាននាក់ពីព្រៃសរមក?

ផលៈ មកប៉ុន្មានទេ ប្រហែល១៥នាក់ ។

ខស្មានៈ ១៥នាក់?

ផលៈ បាទ! ប៉ុនមិនសូវស្គាល់ភ្លេចឈ្មោះគេអស់បាត់ហើយ ។

ខស្មានៈ មានចាំខ្លះទេ?

ផលៈ អត់ចាំទេ! បាត់អស់ហើយ ភ្លេចអស់បាត់ហើយ ។

ខស្មានៈ មានស្រុកកំណើតក្បែរៗគ្នាអត់?

ផលៈ អត់! អត់មាននៅស្រុក ទីឆ្ងាយៗណាស់ ដល់ខ្ញុំមកបែកគ្នាយូអីចឹងទៅ អត់ស្គាល់គេណា បំភ្លេចចោលអស់ទៅណា វាលែងថាអ្នកនេះឈ្មោះនេះអ្នកនោះឈ្មោះនោះអត់ដូចថាយើងបំភ្លេចចោលអស់ទៅ យើងដូចថាមិនយកចិត្តទុកដាក់អារឿងចងចាំអីណា ។

ខស្មានៈ ក្មេងៗបើគេយកចេញពីព្រៃសរមកស-២១ហ្នឹង គេមើលបុគ្គលិកលក្ខណៈយ៉ាងម៉េចទំ?

ផលៈ ដឹងគេមើលម៉េច ។

ខស្មានៈ ឃើញយើងយ៉ាងម៉េចបានគេហៅមក?

ផលៈ ដឹងម៉េចបើគេបញ្ជូនមកហ្នឹង មិនដឹងគេមើលឃើញអាម៉េច ។

ខស្មានៈ ហើយពូមកនៅស-២១ហ្នឹង ពេលដែលលោកពូមកដល់ស-២១ហ្នឹង ពេលដែលដំបូងដែលទើបតែកើតស-២១ ឬក៏ស-២១មានមុនដែលលោកពូទៅដល់ហ្នឹង?

ផលៈ ដឹងជាមានពីឆ្នាំណាមកទេ មកដល់ឃើញគេកាន់ការអីចឹងស្រាប់ៗ ។

ខស្មានៈ ពូអាចនឹងឆ្នាំមើលដែលលោកពូមកនៅស-២១អាចប្រហែលជាឆ្នាំណា?

ផលៈ ចាំមើល៧៥ ក្នុងអំឡុង៧៥ខ្ញុំចូលសាលាយោធា ពាក់កណ្តាល៧៥យើងទៅពីហ្នឹងទៅទៅដលហ្នុង៧៦, ៧៧ ។ ដល់៧៧អីចឹងទៅដល់ទៅនៅខ្ញុំជាអត់បានចាំអារឿងទៅនៅព្រៃកហូរប៉ុន្មានឆ្នាំ ទៅនៅព្រៃសរប៉ុន្មានឆ្នាំវាវាក់ត្រង់ហ្នឹងណា វាវាក់វាភ្លេចអស់បាត់ទៅ អ្នកណាទៅចាំបាន ហើយរាល់ថ្ងៃសួរប្រវត្តិរូបធ្វើពីឆ្នាំណាមកទល់នឹងឆ្នាំណាក៏ខ្ញុំភ្លេចអស់ហើយបាត់ មិនដឹងថ្ងៃទីប៉ុន្មាន ។

ខស្មានៈ បាទត្រូវហើយ! ហើមកនៅស-២១ហ្នឹងគេឲ្យលោកពូធ្វើអី?

ផលៈ ខ្ញុំហ្នឹងវាអត់មានដំណែងអីគេឲ្យធ្វើអីធំដុំទេ ជួនកាលគ្រាន់តែយាម យាមមើលការខុសត្រូវដូចថាអ្នកទោសអ្នកអី អីចឹងទៅណា គ្រាន់តែប៉ុណ្ណឹងទេ មើលដូចថាដើរមើលការខុសត្រូវគេអីចឹងទៅណា ។

ខស្មានៈ ពីណាប្រធាននៅស-២១ហ្នុង?

ផល: ពីដើមគេឲ្យឈ្មោះថា ហ៊ា មួយ...។

ខស្មានៈ ហើមួយទៀត?

ផល: មួយទៀតឈ្មោះប៉េង ខ្ញុំចាំតែពីនាក់ហ្នឹង។

ខស្មានៈ ចុះក្រៅពីហ៊ា, ប៉េងហ្នឹងមានអ្នកណាទៀតជាមេហ្នឹងណា?

ផល: អត់! មានតែមេក្រុមមេអី ត្រង់តែគេចាត់តាំងប្រព័ន្ធគេស្អីៗផ្សេងទៀតខ្ញុំអត់ដឹងទេណា ដឹងអ្នកណាទៅមេណា អ្នកណាទៅមេណី ខ្ញុំអត់ដឹងទេ គ្រាន់តែស្គាល់ឈ្មោះថាប្រធានមន្ទីរឈ្មោះអ៊ីចឹង ហើយបានឃើញទាំងមុខគាត់ដែរ។

ខស្មានៈ ហើពូយាមហ្នឹងយាមម៉េច ដូចថាយាមនៅកន្លែងណា?

ផល: យាមនៅកន្លែងដែលគេមានអ្នកដែលគេចាប់ គេជំរិតយកទៅហ្នឹងគេឲ្យយើងយាម។

ខស្មានៈ យាមហ្នឹងយាមតាមបន្ទប់ ឬក៏យាមនៅ ដាក់វេនយាមនៅកន្លែងណាដែល...?

ផល: យាមវាមានពីរប្រភេទជួនកាលយាមមើលការខុសត្រូវអ្នកផ្ទាល់អ៊ីចឹង ជួនកាលយើងយាមតែតាមផ្លូវទីសាធារណៈផ្សេងអ៊ីចឹងទៅ តាមការគេចាត់តាំងណា គេចាត់តាំងឲ្យយើងយាមផ្លូវ យាមផ្លូវ ចាត់តាំងឲ្យយើងធ្វើអីធ្វើហ្នុងទៅ យើងមានសិទ្ធិណាប្រកែកនឹងគេ។

ខស្មានៈ ចុះភាគច្រើនលោកពូយាមនៅកន្លែងណា?

ផល: ភាគច្រើនយាមនៅកន្លែងហ្នុងម៉ង។

ខស្មានៈ នៅកន្លែងហ្នុងម៉ង?

ផល: បាទ! គ្រាន់តែយើងយាមមើលការខុសត្រូវដូចថា២នាក់, ៣នាក់, ៥នាក់អ៊ីចឹងទៅតែប៉ុណ្ណឹងទេ។

ខស្មានៈ យាមហ្នឹងគេឲ្យតួនាទីសំខាន់ ភារៈកិច្ចពេលយាមហ្នុងគឺស្អីទៅ?

ផល: រឿងគេឲ្យយាមតួនាទីពេលហ្នុង គ្រាន់តែថាគេឲ្យយើងយាម គ្រាន់តែថាមើលការខុសត្រូវខ្លាចក្រែងលោរត់បាត់ ឬមួយក៏មានការឈឺក្រុនស្លាប់រស់ឲ្យយើងដឹងមានការរត់រួចតែប៉ុណ្ណឹងទេ ត្រង់ឲ្យយើងធ្វើសកម្មភាពលើរូបរាងកាយគេគ្មានទេ។

ខស្មានៈ អ៊ីចឹងបើអ្នកទោសឈឺស្លាប់ហ្នឹងត្រូវយ៉ាងម៉េច លោកពូមើលអ្នកទោសហ្នឹងគឺយ៉ាងម៉េច?

ផលៈ យើងរាយការណ៍ប្រាប់គេទៅ បើយើងអត់រាយការណ៍យើងមានទោសទៀត ថាយើងលួចសម្លាប់អ្នកទោសក៏សឹងថាបាន យើងត្រូវទទួលពិន័យទោស ជំនួសអ្នកទោសក៏មានដែរ បើយើងភ្លាមយើងរាយការណ៍ឲ្យគេភ្លាម ។

ដារ៉ាៈ បងច្រើនតែរាយការណ៍ជូនអ្នកណា?

ផលៈ បាទ! រាយការណ៍ អស់....SideA......

## SideB

ផលៈ ឈ្មោះគន ។

ឧស្មានៈ គាត់នៅរស់ទេ?

ផលៈ អត់ទេក្នុងសម័យហ្នុង គាត់ដឹងសាងអំពើអីមួយទេណា ខ្ញុំមិនបានដែលរឿងកស្តុតាងហ្នឹង ក៏ក្នុងមន្ទីរហ្នឹងគេចាប់ដាក់គុក ដោយនៅក្នុងហ្នឹងដែរ គាត់ត្រូវស្លាប់នៅក្នុងគុកហ្នុងអាដែលប្រធានក្រុមរបស់ខ្ញុំហ្នឹងណា គាត់អត់មានបានរស់ទេ ។

សុជាៈ គាត់ស្លាប់នៅក្នុងឆ្នាំណាដែលបង?

ផលៈ ស្លាប់ហ្នឹងដឹងឆ្នាំប៉ុន្មានដែរខ្ញុំអត់បានដឹងអារឿងហ្នឹងទេ ប៉ុនអារឿងស្លាប់មិនដឹងរស់មិនដឹង ប៉ុន្តែប្រាកដតែគេចាប់ដាក់គុក ។

សុជាៈ ដឹងប្រាកដតែគេចាប់ដាក់គុក?

ផលៈ បាទ! ចាប់ដាក់គុកក្នុងហ្នឹងដែរ ។

ដារ៉ាៈ អីចឹងប្រធានក្រុមបងហ្នឹងចាប់ដាក់គុកគាត់មានកំហុសអី?

ផលៈ ដឹងមានកំហុសអី ព្រោះខ្ញុំមាននាទីត្រឹមតែយាមហ្នឹងដែរ ។

សុជាៈ បងបានយាមប៉ះគាត់ទេ?

ផលៈ យាមអត់ប៉ះទេ ប៉ុន្តែយើងចាប់ថ្មីៗ គេបញ្ជូនដាក់កន្លែងផ្សេង គេអត់ឲ្យក្នុងក្រុមគ្នីគ្នាឯងហ្នឹងឃើញ បញ្ជូនទៅផ្សេង ។

សុជាៈ ហើយបងបានឃើញប្រធានក្រុមបងនៅក្នុងមន្ទីរឃុំឃាំងហ្នឹងយូទេ?

ផលៈ ហ្នឹងហើយ!

សុជាៈ នៅយូទេ?

ផលៈ អត់យូប៉ុន្មានទេ ។

សុជាៈ ហើយគេបញ្ជូនចេញទៅ?

ផលៈ  អត់! អត់ដឹងទេ អត់ដឹងគេបញ្ជូនចេញទៅណាទៅណីទេ ប៉ុនកន្លែងនេះ តែពួកធ្វើការ
កន្លែងហ្នុង តែចាប់ហើយកម្រួចខ្លួនណាស់ទាំងរូបគេទាំងរូបខ្ញុំ ទាំងអស់ទូទៅ ។

សុជាៈ  មិនរួចទៅណាវិញទៅបង?

ផលៈ  គេយកសម្លាប់ចោល?

ខស្នានៈ គេសម្លាប់ចោល! គេសម្លាប់នៅឯណាដែរ?

ផលៈ  ដឹងគេសម្លាប់យកទៅណាបើឃើញតែគេទៅទៅ គេអ្នកធំៗណា គេដាក់ទាំងឡានទៅ
បាត់ៗអស់ទៅ ។

ខស្នានៈ ចុះក្នុងម៉ោពេលដែលបងយាមនៅកន្លែងហ្នុង បងដែលជួបមនុស្សដែលបងស្គាល់គ្នាត្រូវ
ចាប់យកទៅដាក់ហ្នុងអី?

ផលៈ  អត់ដែរស្គាល់ទេ!

ខស្នានៈ ដែលយាមប៉ះអ្នកស្គាល់ទេ?

ផលៈ  អត់ដែរស្គាល់ទេ! ដូចថាមកពីណេះមកពីណុះអីចឹងមក ។

ដារ៉ាៈ  អីចឹងបងយាមនៅខាងក្នុង ឬខាងក្រៅបង?

ផលៈ  យាម?

ដារ៉ាៈ  បាទ!

ផលៈ  ជួនកាលខាងក្នុងទៅជួនកាលខាងក្រៅអីទៅ ។

ដារ៉ាៈ  ខាងក្នុងបងសំដៅកន្លែងណាខាងក្នុង?

ផលៈ  តាមគេចាត់តាំង ។

ដារ៉ាៈ  អត់ទេ! កន្លែងដែលបងយាមខាងក្នុង ចង់សួរបងថានៅកន្លែងអាគារគុក ឬក៏...?

ផលៈ  អាគារអ្នកដែលគេដាក់អ្នកទោសហ្នុងនោះ ។

ដារ៉ាៈ  តាមបន្ទប់តាមអីហ្នុងឬ?

ផលៈ  បាទ!   បើគេចាត់តាំងទៅកន្លែងណា យើងទៅធ្វើការឲ្យគេកន្លែងហ្នុងទៅយើងប្រឆាំង
គេធ្វើម៉េចបាន អត់បានទេ ។

ខស្នានៈ ចុះបងឃើញសភាពអ្នកទោសយ៉ាងម៉េចទៅ?

ផលៈ  ឃើញវាលំបាកហ្នុងហើយ ។

ខស្នានៈ ឃើញស្អីខ្លះដែលបងគិតថាលំបាក?

ផល: លំបាកអារឿងថាមនុស្សយើងយកមកហើយ ដាក់គេក្នុងទោសក្នុងអីអីចឹងទៅ ដល់ពេលដែលយើងនៅការពារ យើងនៅធ្វើការកន្លែងហ្នឹងអីចឹងទៅ ដល់គេយកសួរចម្លើយសួរអីចឹងទៅ គេវៃគេអីអីចឹងទៅ វាឃើញលំបាកដែរ មកវិញអីចឹងទៅមានគេវៃមានគេអីចឹងទៅវារបេករបកអីចឹងទៅ វាក្រទីក្រទួលអីចឹងទៅយើងក៏លំបាកមើលប៉ុន្តែយើងក៏មិនដឹងគេចវេសទៅឯណា ។

សុជា: ហីពូដែលឃើញគេវៃអ្នកទោសទេ?

ផល: អត់ដែលឃើញទេ ។

សុជា: តើហេតុអីបានពូដឹងថាគេធ្វើបាបអ្នកទោស?

ផល: ម៉េចមិនដឹងបើគេយកមកវិញ មិនមានស្លាកស្នាមរបួសមកវិញ យកមកប្រគល់ឲ្យយើងអ្នកមើលការខុសត្រូវហ្នឹងវិញ ។

សុជា: ហើយអ្នកទោសហ្នឹងដែលនិយាយប្រាប់បងពីការលំបាករបស់គេទេ?

ផល: និយាយអីចឹងដែរ ប៉ុន្តែថានិយាយទៅក៏យើងមិនដឹងជាជួយរបៀបម៉េច ហើយយើងក៏មិនដឹងជាថារបៀបម៉េច ។

សុជា: គេនិយាយថាម៉េចខ្លះ?

ផល: គេនិយាយៗថាពិបាក មិនដឹងជាខុសស្អីផង និយាយតែនិយាយអីចឹង មិនដឹងខុសស្អីផងយកមកដាក់ទោសអីចឹងទៅ ។

សុជា: ហីក្នុងចំណោមអ្នកទោសម្នាក់អីចឹង គេយកទៅសួរចម្លើយប៉ុន្មានដង?

ផល: ប៉ុន្មានដងជួនកាលគេយកទៅសួរជួនកាលខ្លះទៅ ក៏គេយក៤ដង ខ្លះក៏គេយក៤ដង ខ្លះគេយក៣ដង ខ្លះគេយករហូតដល់៥ដងអីចឹងទៅ ។

សុជា: ហើយបន្ទាប់ពីសួរចម្លើយមកគេយកទៅណាទៀត?

ផល: ដឹងគេថាគេបញ្ជូន ដឹងបញ្ជូនទៅខាងណាទៀត ដឹងគេបញ្ជូនយកទៅមន្ទីរណាទៀតក៏មិនដឹងដែរណា គេថាបញ្ជូនៗហើយ យើងដឹងតែគេបញ្ជូនហើយ ដឹងបញ្ជូនទៅទីកន្លែងណា ។

សុជា: ចុះពូគិតខ្លួនឯងថាគេបញ្ជូនចេញហ្នឹង គេបញ្ជូនទៅម៉េចអ្នកទោសហ្នឹង?

ផល: គិតខ្លួនឯង គិតខ្លួនឯងទើបហ្នឹងដឹងយើងរំដោះរួចបានដឹងថា អូ! បញ្ជូនទៅមិនមែនបញ្ជូនសហករណ៍វិញទេ ឬមួយក៏គេបាននិយាយថា គេសួរសម្លើយរួចគេធ្វើការរួចគេបញ្ជូន បានន័យថាគេបញ្ជូនទៅសហករណ៍វិញ រួចទៅទីកន្លែងវិញ ហើយខ្ញុំក៏អត់

បានដឹងដែរម៉ោរាជហ្នុងណា ដល់ទើបសម័យរំដោះរួច បានដឹងថាបញ្ជូនមកសុទ្ធតែសម្លាប់ចោល អាហ្នឹងបានទើបនឹងដឹងបច្ចុប្បន្នហ្នឹង ។

ឧស្មានៈ ម៉េចបានដឹង?

ផលៈ បានដឹងចុះយើងរាល់ថ្ងៃមិនដឹង បើក្បាលគរគោកគរដីនោះនិយាយម៉េចថាមិនដឹង ហើរាជរដ្ឋាភិបាលយើងរាល់ថ្ងៃ គាត់មិនចាជាកាសែតគរគោកគរដីសម្រាប់យើងមើល យើងមិនដឹង កាលគេថាបញ្ជូនទោសបាករណ៍ បញ្ជូនទៅន្លែងនេះកន្លែងនោះ អ្នកនេះរួចទោសហើយ គេឲ្យទៅវិញ ។

ឧស្មានៈ គេប្រាប់យើងអ្នកយាមអីចឹង?

ផលៈ បាទ!

សុជាៈ ហើអ្នកមកយកហ្នុងមិនមែនជាអ្នកយាមទេបង?

ផលៈ មិនមែនទេ! គេបញ្ជូនទៅតាមហ្នឹងទៅតែទាំងអស់ទៅទៀតទៅ ដឹងគេបញ្ជូនយកទៅដាក់ឯណាដាក់ឯណីខ្ញុំអត់បានដឹងទេ ។

ឧស្មានៈ ចុះវេណយាមគេឲ្យលោកពូយាមយ៉ាងម៉េច?

ផលៈ យាមៗពេលយប់ពេលថ្ងៃអីចឹងទៅ ។

ឧស្មានៈ ក្នុងមួយថ្ងៃមួយយប់អីចឹងប៉ុន្មានវេណ?

ផលៈ ពីរ!

ឧស្មានៈ ពូយាមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ផលៈ ពីម៉ោង៦ល្ងាចដល់ម៉ោង១យប់ ហើនុយដេកចុយម៉ារាយ ស៊ើច...

ឧស្មានៈ ហើចុះថ្ងៃពូមានយាមទៀតទេ?

ផលៈ ថ្ងៃយើងស៊ីបាយរួចចូលដូរគេវិញ ។

ឧស្មានៈ ម៉ោងប៉ុន្មាន?

ផលៈ ចូលដូរម៉ោង១វិញ គេសម្រាក ដល់ម៉ោង៦ល្ងាចបានគេដូរវិញ ។

ឧស្មានៈ ហើយពូអាចដូចថាពូអង្គុកអី អាចនិយាយលេងជាមួយអ្នកទោសនៅហ្នុងបានទេ?

ផលៈ និយាយគេឲ្យនិយាយបាន ប៉ុន្តែរឿងនិយាយការម៉េចៗអត់បានទេ គេនិយាយគេថាឲ្យយើងចេះតែលួងលោមទៅ ចេះតែ...ទៅណាកុំឲ្យអ្នកទោសហ្នុងកើតទុក្ខ ដើម្បីគេយកទៅសួរចម្លើយអាហ្នឹងការងារគេផ្សេង អ្នកយាមគេឲ្យចេះធ្វើនយោបាយសម្រាប់អ្នកទោសអារឿងដែលគេយកទៅអាហ្នឹងការងារគេផ្សេង ។

ខស្មានៈ ចុះគេឲ្យលោកពូនិយាយក្នុងនិយាយក្នុងន័យថានិយាយលួងលោមអីចឹង?

ផលៈ អ៊ឺ!

ខស្មានៈ លួងលោមយ៉ាងម៉េចខ្វះ?

ផលៈ យើងគ្រាន់តែថាអីចឹង គេបញ្ជូនទៅ គេឲ្យមកផ្ទះមកអីវិញ អីចឹងទៅតាមអាការដែលគេថា ការដែលយើងឃើញអីចឹងណា ការដែលយើងឃើញថាពេលគេចាប់ ទៅគេឲ្យមកផ្ទះវិញ ឃើញតែមកបាត់ៗអស់មក យើងមិនដឹងគេយកទៅកន្លែងណា គេបញ្ជូនទៅកន្លែងណា គេថាឲ្យទៅសហករណ៍វិញគេឲ្យទៅអង្គភាពវិញ ពុំតែអីចឹង ហើយខ្ញុំមិនបានទៅតាមមើលឯណា បើដែនការគេឲ្យតែទៅហ្នឹង យើងដើរបាត់អាហ្នឹងដែនការគេទៀត ។

ខស្មានៈ ចុះបើនិយាយក្រៅពីនិយាយអីចឹងបានទេ និយាយដូចសួរសុខទុក្ខ ស្រុកកំណើតនៅឯណា?

ផលៈ ជីមិនបានស្រុកកំណើត...។

ខស្មានៈ សួរអីផ្សេងៗទៀត?

ផលៈ អារឿងសួរស្រុក សួរកំណើតអាហ្នឹងបានថាពិបាកដែរ ។

ខស្មានៈ ពិបាកម៉េចទៅ?

ផលៈ ពិបាករឿងសួរអីចឹងៗវាពិបាកដែរ ។

សុជាៈ គេហាមឃាត់ប៉ុបង?

ផលៈ គេហាមឃាត់ គេអត់ឲ្យសួរអីច្រើនអារឿងអីចុងៗទេ ។

ខស្មានៈ បើនិយាយ ក្នុងនិយាយលួងលោម?

ផលៈ អើ! បើនិយាយដូចថាឥឡូវគេថាឲ្យធ្វើអីចឹងទៅ ដូចថាឥឡូវក្នុងដែនការគេហ្នឹងគេធ្វើម៉េចៗគេឲ្យលួងគេឲ្យលោមក្នុងការងារហ្នឹងអីចឹងទៅយើងគ្រាន់ថាវាអត់អីអីចឹងទៅ កុំឲ្យអ្នកទោសហ្នឹងមានការថាម៉េចច្រួលច្របល់ច្រើនយើងអាចនិយាយលេងបាន តែអាក្នុងដែលយើងនិយាយខុសឆ្គង កាលណាគេយកអ្នកទោសយកសួរសចម្លើយអីចឹងណា យកអ្នកទោសសួរចម្លើយជូនកាលក្នុងបញ្ជីហ្នឹងវាមានច្រើនណាស់ អ្នកយាមទៅជាប់គុកជិន្ទួសវាមានច្រើន ។

ខស្មានៈ ហេតុអី?

ផលៈ ហេតុអីបានតែជាប់ អាហ្នុងចេះតែថា វាជាប់ខបមាថា យើងសួរលិចសួរកើត ដល់តែក្នុងឯកសារដែលគេយកទៅសួរចម្លើយអីចឹង ទៅអ្នកទោសហ្នឹងនេះទៅឆ្លើយដាក់យើង ដល់ឆ្លើយដាក់យើង យើងមានឈ្មោះ គេចាប់យើងទៀត វាអីចឹង មិនមែនថាស្រេចយើងធ្វើតាមអីពើចិត្តទេណា តែមានគេយកទៅសួរចម្លើយអីចឹងណា សួរចេញជាឯកសារអីចឹងណា តែឃើញក្នុងហ្នឹងគេចាប់យើងទៀត ហីគេវ៉ៃយើងទៀត គេធ្វើបាបយើងពេលហ្នុងទៀត ។

ខស្នានៈ ចុះដែលមានករណីហ្នឹងដាក់ស្ដែងកើតឡើងទេ?

ផលៈ មាន!

ខស្នានៈ ឈ្មោះអីដេលគេចាប់ហ្នុង?

ផលៈ ឈ្មោះដែង ឈ្មោះវាមាន អ្នកចាប់ក៏វាមាន មានដូចថាយើងលាក់ ដូចថាដែលអាហ្នឹងតាមនេះទៅវាអីចឹងដែរចាប់ ។

ខស្នានៈ ឈ្មោះអីអ្នកយាមដែលគេចាប់ហ្នុង?

ផលៈ អ្នកយាមចាប់មួយទៀត ដូចថាឈ្មោះថេតអីចឹង?

ខស្នានៈ ថេត! គាត់បាននិយាយលេងជាមួយអ្នកទោសអីចឹង?

ផលៈ ហ្នឹងហើយ! គាត់មិនបាននិយាយលេងទេ គាត់ជាតួនាទីប្រធានក្រុមខ្ញុំពីមុនទៅទៀត គេចាប់គាត់ហ្នឹងហើយ គេចាប់គាត់ទៅមានរឿងអី គេថាយើងហ្នឹងមានឯកសារគ្រប់គ្រាន់គេវ៉ៃគាត់ធ្វើបាបគាត់អីចឹងទៅ ។

ខស្នានៈ រួចគាត់ហ្នុងមានដោះលែងឲ្យរួចខ្លួនវិញទេ?

ផលៈ ខ្ញុំអត់ដឹងដែរ គេបញ្ជូន ប៉ុន្មានថ្ងៃដែរគេចាប់គាត់យកមកដាក់នៅកន្លែងខ្ញុំហ្នឹងម៉ាយប់ដែរពីរដែរ ។

ខស្នានៈ លោកពូអ្នកយាមគាត់?

ផលៈ បាទ! ប្រធានក្រុមខ្លួនឯងខ្ញុំអ្នកយាមទៀត ។

ខស្នានៈ ហើយអាចនិយាយបានទេ និយាយ....?

ផលៈ និយាយចេះតែបានហើយប៉ុន្តែថាយើងកាលណាដូចតែគេចាប់អីចឹងណា ដូចគេចាប់ប្រធានក្រុមមួយហើយ ខ្ញុំអ្នកយាមហ្នឹងមានការព្រួយចិត្តណាស់ ប្រធានក្រុមគេចាប់ទៅហើយ តែចេញឯកសារមកទិចមានខ្ញុំ តិចមាននេះតិចមាននោះ ពេលហ្នុងភ័យចំពោះគាត់ឆ្លើយមកហ្នុងទៅ វាជាប់ដល់យើង យើងអាចទៅទៀត ។

ខស្មានៈ ចុះអ្នកទោសហ្នឹង គឺហូបចុកហីយ៉ាំងម៉េចដែរ?

ផលៈ ពេលហូបចុកតាមរបបគេ ។

ខស្មានៈ របបយ៉ាំងម៉េចទៅ?

ផលៈ របបគេ គេយកមកអីចឹងគេឲ្យហូបតាមរៀងខ្លួនហ្នឹងដែល គេអ្នកឲ្យរបបហ្នុងគេឲ្យផ្សេង ទៅ គេជួសដើររៀបដើរអីឲ្យនីចឹងទៅតាមលក្ខណៈគេដែល....

ខស្មានៈ បានអីហូបទៅ?

ផលៈ ជួនកាលសម្លត្រី ជួនកាលអីចឹងទៅណា ។

ខស្មានៈ ចុះម្ហូបបាយអីអាចគ្រប់គ្រាន់គំរូវសម្រាប់អ្នកទោសម្នាក់ៗទេ?

ផលៈ ជួនកាលគ្រប់ទៅ ជួនកាលក៏អត់អីចឹងដែរ វាមិនមែនតែគ្រប់រហូតទេណា ។

ខស្មានៈ ហើយចុះពីណាអ្នកដែលបែងចែកម្ហូបអាហារហ្នឹង អ្នកយកម្ហូបហ្នឹងយកមកឲ្យ?

ផលៈ ខាងសេដ្ឋកិច្ចគេ ។

ខស្មានៈ ខាងសេដ្ឋកិច្ចគេផ្សេង?

ផលៈ បាទ! ខាងសេដ្ឋកិច្ចគេ ប៉ុនខ្ញុំអត់បានស្គាល់ឈ្មោះគេទេខាងសេដ្ឋកិច្ចហ្នុង ។

ខស្មានៈ ចុះម្ហូបសម្រាប់អ្នកទោស ហឺសម្រាប់លោកដែរជាអ្នកយាមហ្នឹងមានការខុសប្លែកគ្នា ដែរឬអត់?

ផលៈ វាខុសគ្នា ។

ខស្មានៈ ម្ហូបផ្សេងៗគ្នាអីចុង?

ផលៈ បាទ! ផ្សេងៗគ្នា ។

សុជាៈ លោកពូអ្នកទោសដែលជាប់ពន្ធនាគាហ្នឹង ឧបមាថាពេលដែលមានជម្ងឺឈឺថ្កាត់អី មាន ពេទ្យអីគេមើលទេ?

ផលៈ ពេទ្យគេមើល ប៉ុន្តែដឹងគេមើលវិធីណាមួយយើងអត់ដឹងទេណា មើលយកចិត្តទុកដាក់ ដោយវិធីណាមួយខ្ញុំអត់ដឹងដែរ ឃើញតែគេមើលអីចឹងដែរ ។

សុជាៈ មើលយ៉ាំងម៉េចបង?

ផលៈ គេមើលគេចាក់ថ្នាំ ចាក់អីឲ្យអីចឹងដែរ ប៉ុន្តែគេចាក់ថ្នាំអី គេយកចិត្តទុកដាក់របៀបម៉េច ណា ។

សុជាៈ ចុះពូមានដែរឃើញអ្នកទោសដេកស្លាប់ដោយសារជម្ងឺនៅក្នុងគុកទេ?

ផលៈ អត់! អត់សូវមានទេ ។

ខស្នាន: មានដែរ ឬក៏អត់?

ផលៈ និយាយហ្នឹងក្រែងលោផ្នែកគេណា ប៉ុន្តែផ្នែកខាងខ្ញុំអត់មានទេ ។

សុជាៈ ចុះពូដែលពួកគេខាងណុះនិយាយថាមានអ្នកទោសដេកស្លាប់អីទេ?

ផលៈ ខាងណា?

សុជាៈ ខាងគេផ្សេងៗ ទៀតណា?

ផលៈ ដូចអត់សូវទាក់ទងគ្នាប៉ុន្មានទេ ខ្ញុំទៅៗខ្ញុំមកវិញមកការងារវាផ្សេងៗពីគ្នា ។

ខស្នាន: ចុះការផ្ទួតទឹកអីអ្នកទោសគេឲ្យផ្ទួតទេ?

ផលៈ ការផ្ទួតទឹកគេបាញ់ទឹកទុយយោឲ្យផ្ទួតអីចឹងទៅ ទឹកទុយយោពេញៗផ្ទះ ។

ខស្នាន: ទឹកទុយយោយ៉ាងម៉េច?

ផលៈ ទឹកទុយយោ ទឹកម៉ាស៊ីនយើងហ្នឹង ប៉ុនវាមិនបានជាប់រាល់ថ្ងៃ ។

ខស្នាន: ប៉ុន្មានថ្ងៃផ្ទួតម្តង?

ផលៈ ៣ថ្ងៃអីចឹងទៅ ១ថ្ងៃ, ២ថ្ងៃអីចឹងទៅណា អាហ្នឹងគេថាម៉េចជាប់គុកវាតែងតែ... ។

ខស្នាន: រួចគេដោះពីខ្នោះហ្នឹង?

ផលៈ អត់ទេ! គេអត់ឲ្យដោះទេ ។

ខស្នាន: អត់ឲ្យដោះទេ?

ផលៈ បាទ!

ខស្នាន: ហីចុះខោអីផ្លាស់បានទេ?

ផលៈ ខោអីយើងស្លៀកអីចឹងទៅ យើងដូរដើង ។

ខស្នាន: ដូរដើងយ៉ាងម៉េច?

ផលៈ ដូរដើងខបមាយើងដាក់ ស៊កម៉ាចំហៀងហ្នឹងរួចយើងដាក់អាហ្នឹងឲ្យគេវិញទៅ យើងឲ្យគេស៊កដើងមួយចំហៀងទៀត ឲ្យគេស្លៀកទៅ គេអង្គុយទៅ មិនអីចឹង!

ខស្នាន: បាទ!

ខស្នាន: នៅពេលដែលផ្ទួតទឹកហ្នឹង និយាយផ្លាស់មានស្អី ក្រមាមានអីផ្លាស់ធម្មតាដែលអត់?

ផលៈ ក្រមាអីមាន ។

ខស្នាន: មានទេ?

ផលៈ មាន! សម្រាប់ឲ្យតែមាផ្លាស់ហ្នឹងទេ បើក្រៅពីហ្នឹងអត់... ។

ខស្នាន: អីចឹងមុជហ្នឹងដើងនៅជាប់ទេ?

ផលៈ ដើងនៅជាប់ទេ ។

ខស្នានៈ មុជនៅកន្លែងហ្នឹង?

ផលៈ បាទ!

ខស្នានៈ ចុះពេលមុជហើយទឹកមិនដក់នៅ?

ផលៈ ដក់នៅអី យើងលើអាជែងឥដ្ឋយើងហ្នុងវាអត់ជិតទេ តែនេះទៅវាហូរ យើងទូតរូច យើងជូតទៅណា ជូតរួចហូរទៅអស់មានទៅស្អី ប៉ុន្តែវាមិនបានជាប់រាល់ថ្ងៃ ២ថ្ងៃម្តង ៣ថ្ងៃម្តងអីចឹងទៅ ។

ដារ៉ាៈ ចុះបងនៅក្នុងមន្ទីរស-២១ហ្នឹងមានក្រុមអីខ្លះទៅ?

ផលៈ ក្រុម?

ដារ៉ាៈ បាទ! ដូចថាក្រុមយាមក្រុមអីខ្លះ?

ផលៈ ក្រុមមានតែក្រុមយាមមួយ ហើយនិងក្រុមសួរចម្លើយមួយមានប៉ុណ្ណឹង ។

ដារ៉ាៈ មានក្រុមចាប់ទេ?

ផលៈ ក្រុមចាប់ក៏មានដែរ ប៉ុនគេជ្រើង ។

ដារ៉ាៈ មិនមែននៅក្នុងមន្ទីរស-២១ទេ?

ផលៈ ដឹងនៅឯណាដែរឃើញតែគេមកអីចឹង គេដាក់ឡានដាក់អីមកអីចឹង ចុះយើងថាម៉េច យើងធ្វើតាមគេណា ។

ដារ៉ាៈ ចុះបងនិយាយថាមានតែក្រុមយាម ក្រុមសួរចម្លើយអីចឹងឬ?

ផលៈ ក្រុមសួរចម្លើយ ក្រុមចាប់វាមានដែរ ប៉ុនមិនដឹងនៅក្នុងអង្គភាពហ្នុងដែរ ហ៊ីក៏គេអាម៉េចអាហ្នុងក្រុមគេផ្សេងណា ។

ដារ៉ាៈ ចុះក្រុមឯកសារអី?

ផលៈ ក្រុមឯកសារអាហ្នុងក្រុមអ្នកសួរចម្លើយហ្នុងហើយ បានប៉ុន្មានៗអាហ្នុងរឿងគេអ្នកឆ្លើយហ្នុងហើយណា ។

ខស្នានៈ ចុះអ្នកយាមសរុបទាំងអស់ប៉ុន្មានបង?

ផលៈ អត់ទៀង អត់ភ្លាប់បានទេ ព្រោះខ្ញុំកាលហ្នុងដូចខ្ញុំបានជំរាបថាខ្ញុំក្មេង ខ្ញុំកាន់ការងារតែមួយមុខទេណា ខ្ញុំអត់បានមានបញ្ជីអីឯណា ស្រាវជ្រាវអីខ្ញុំអត់ដឹងទេណា ។

ខស្នានៈ ចុះលោកពូក្រៅពីភារៈកិច្ចយាម ក្រោយមកទៀតមានធ្វើកិច្ចការអីផ្សេងក្រៅពីយាមទៀតទេ?

ផលៈ   អត់ទេ!

ខស្នានៈ យាមហ្នុងតែរហូត?

ផលៈ   បាទ! យាមហ្នុងរហូត ។

ខស្នានៈ ចុះអ្នកទោសម្នាក់ជាធម្មតាគេដាក់នៅកន្លែងហ្នុងរយៈពេលប៉ុន្មានបានយកចេញ?

ផលៈ   តាមអត់ទៀង ជួនកាលទៅក៏យូទៅ ជួនកាលទៅក៏ឆាប់ទៅ ។

ខស្នាន: យូហ្នុងរយៈពេលប៉ុន្មាន?

ផលៈ   យូហ្នុងបែបជាទំនងម៉ាខែអីចឹងទៅ ។

ខស្នាន: ចុះឆាប់?

ផលៈ   ឆាប់បែបជាម៉ាអាទិត្យជាងអីចឹងទៅ ។

ខស្នាន: ចុះអាម៉េចបានមានការខុសគ្នាអីចឹង ហេតុហី?

ផលៈ   ...បើនិយាយទៅ សួរគេ គេថាតាមទោស អាហ្នឹងបានថានៅពេលគេសម្លាប់ចោល ខ្ញុំអត់បានដឹងទេណា ដល់មក៧៩គេថាសម្លាប់ចោល ដូចឃើញឯកសារ ឃើញអាដែងគេគាស់ក្បាលខ្មោចក្បាលអីមកបានថា អូ! ពួកនេះអត់មានឲ្យមកផ្ទះណា គេសម្លាប់ចោលតើវាអីចឹង ។

ខស្នាន: ហើលោកពូដែលបានមើលឃើញ ដូចអ្នកគេយកទៅស្លូចម្ល៉ើយណា?

ផលៈ   អត់ឃើញគេយកទៅឆ្ងាយ ។

ខស្នាន: ដែលបានឮសម្រែក ឮអីទេ?

ផលៈ   ឮ! ប៉ុនឮអាកន្លែងគេជិតៗណា កន្លែងខបមាថាចុះទៅនៅជ្រាលអាចឮអីចឹងដែរណា ប៉ុន្តែអាកន្លែងគេយកទៅឆ្ងាយៗ វាអត់ឮដែរទេណា ។

ខស្នាន: ស្រែកហ្នុងលោកពូគិតថាយ៉ាងម៉េច?

ផលៈ   ស្រែកហ្នុងបានន័យថាគេវ៉ៃ គេធ្វើបាបហ្នុង ។

ខស្នាន: ចុះមានឮសម្លេងវ៉ៃហ្នឹងទេ?

ផលៈ   វ៉ៃដូចមិនសូវមានឮទេ ពួកហ្នុងវាច្រើនមានដូចថាឆក់ខ្សែភ្លើង ឆក់អីចឹងវិញទេ ។

ខស្នាន: ចុះលោកបានឃើញអ្នកទោសមានជនជាតិអីផ្សេងពីខ្មែរទេ?

ផលៈ   មាន!

ខស្នាន: ជនជាតិអី?

ផលៈ   ជនជាតិថៃក៏មាន អាហ្នឹងតាមខ្ញុំធ្លាប់ឃើញ បែបគេបញ្ជូនណា ។

ខស្នានៈ ថៃប៉ុន្មាននាក់?

ផលៈ ថៃប្រហែលជា៤-៥នាក់ប៉ុណ្ណឹងទេ ។

ខស្នានៈ នៅឆ្នាំណាពូឃើញអ្នកទោសថៃ?

ផលៈ ឆ្នាំ៧៧ ។

ខស្នានៈ ហើចុះអ្នកទោសផ្សេងទៀតជនជាតិក្រៅពីថៃ?

ផលៈ ថៃ! ប្រទេសណាក៏មានដែរ មានច្រើន ថៃ, យួន ។

ខស្នានៈ ចុះមានឃើញអ្នកទោស...

ផលៈ ដល់មែនទែន ជាប់ទោសដល់អ្នកពួង សុទ្ធជនជាតិព្នងទៀត ។

ខស្នានៈ ព្នងមានដែរ?

ផលៈ បាទ!

សុជាៈ ថីបានពូដឹងថាមានព្នង?

ផលៈ មានណា! បើយកទៅខ្ញុំឃើញ ។

ខស្នានៈ ហើយចុះជនជាតិស្បែកសរគាត់មានទេ?

ផលៈ បើជនជាតិនេះមាន ជនជាតិរូមម៉ានី ណា ។

ខស្នានៈ រូមម៉ានី?

ផលៈ បាទ!

សុជាៈ ចុះម៉េចបានពូដឹងថារូមម៉ានីពូ?

ផលៈ ចុះបើឃើញបញ្ជូនមក ។

សុជាៈ គេបញ្ជូនមកគេដាក់ឯកសារអីភ្ជាប់នៅហ្នឹង?

ផលៈ អត់ទេ! គេដូចថា គេបញ្ជូនចូលមកតាមទ្វារអីចឹងទៅ យើងសួរគេទៅថាជនជាតិអីសរម្ល៉ឹង ឬមួយខ្ពស់ម្ល៉ឹង គេថាជនជាតិរូមម៉ានីអាហ្នឹងយើងដឹង ។

សុជាៈ ចុះដល់ពេលពេលជនជាតិព្នង ឬជនជាតិវៀតណាមអីមកគេប្រាប់អីចឹងទៅ?

ផលៈ គេអត់ប្រាប់ទេ! វៀតណាមយើង...

សុជាៈ យើងដឹង!

ផលៈ យើងដឹង ។

សុជាៈ រួចថៃ?

ផលៈ បាទ!

សុជាៈ ថ្ងៃយើងដឹងដែរ?

ផលៈ ថៃក៏យើងដឹងដែរ ។

សុជាៈ ពូធ្លាប់យាមប៉ះដែរ?

ផលៈ បាទ! ប៉ុនខ្ញុំអត់បានយាមជាប់ទេណា គ្រាន់តែមួយថ្ងៃអីហ្នឹងគេដូរឡើងបាត់ទៅហើយ ។

សុជាៈ រួចអីចឹងជនជាតិព្នង ជនជាតិវៀតណាម ថៃអីហ្នឹងពូធ្លាប់យាមប៉ះដែរ?

ផលៈ យាមបានមួយយប់អីហ្នឹង បើក្រៅពីហ្នឹងគេដកបាត់ ទៅកន្លែងគេផ្សេង ។

សុជាៈ នៅកន្លែងគេផ្សេង?

ផលៈ ហ្នុងហើយ ។

ឧស្មានៈ ចុះអ្នកទោសធំៗ អ្នកធំៗណាពូដែលបានយាមទេ?

ផលៈ អត់! អត់បានទេ អានោះថ្នាក់គេផ្សេងតាមខ្ញុំដឹងណា អានោះថ្នាក់គេផ្សេង គេអ្នកយុវជនពេញវ័យនោះណា ដូចខ្ញុំអីហ្នឹង អាហ្នឹងបានតែអ្នកទោសដូចថា ខ្សោយតិចតួច អានេះគ្រាន់តែឲ្យជួយបំពេញណា អានេះជាវ័យកុមារនៅឡើយដែរណា វាមិនទាន់ពេញសិទ្ធិហ្នឹងគេណា ធំៗហ្នុងគេថ្នាក់ធំៗទេ ។

ឧស្មានៈ អ្នកធ្វើការនៅកន្លែងហ្នុង រាល់ថ្ងៃលោកពូមាននៅចាំទេ ថាអ្នកណារស់នៅកន្លែងណាខ្លះទេអ្នកធ្វើការនៅកន្លែងហ្នុង?

ផលៈ អ្នកធ្វើការកន្លែងហ្នុងអត់! ទៅជាមួយខ្ញុំក៏បាត់អស់ ហើក្រៅពីហ្នឹងទៀតអត់មានដឹងថាអ្នកណានៅរស់អ្នកណានៅក៏អត់ដែរ ។

ឧស្មានៈ លោកពូអត់ដែលដឹង អត់ដែលបានជួបមុខគ្នាទេ?

ផលៈ អត់ដែលបានដើរជួបគ្នា ប៉ុន្តែខ្ញុំជួបបានម្នាក់ទេ ដែលកាលនៅរស់នោះ ។

ឧស្មានៈ នៅណា?

ផលៈ ប៉ុនជួបតែមុគងគត់ ប៉ុនឥឡូវដឹងគាត់ស្លាប់ ដឹងគាត់រស់ណា ។

ឧស្មានៈ បាទ!

ផលៈ ឈ្មោះ ជន មួយទេ ប៉ុនដឹងនៅឃុំណាផងទេ ជួបម្នាក់ ។

ឧស្មានៈ នៅក្នុងស្រុកអីដែរ?

ផលៈ ជួបតាំងពីយើងរំដោះរួចថ្មីហ្នុងណា?

ឧស្មានៈ ជន នៅស្រុកអី?

ផលៈ អត់បានដឹងស្រុកហ្នុងផង ។

ដារ៉ាៈ ដឹងឈ្មោះកំណើតគាត់ទេ?

ផលៈ អត់!

ខស្នានៈ ជួបនៅកន្លែងណា?

ផលៈ ជួបនៅរមាស តែអត់បាន ជួបដូចថាយើងមកពី...មកវិញអីចឹងណា អើយើងចុះមក យើងមកហ្នឹងវិញហើយណា ជួបបានម្តងហ្នុងបាត់រហូតទោដឹងប៉ុន្មានឆ្នាំហើយ យើង២០ ឆ្នាំជាងហើយណា ។

សុជាៈ ហើគាត់ឈ្មោះ ដន ហ្នុងគាត់ធ្វើអីដែរនៅ....?

ផលៈ អត់ធ្វើអីទេ! កុមារដូចខ្ញុំអីចឹងដែរ ។,

សុជាៈ ហើពូសម័យពូយាមនៅគុកទួលស្លែងហ្នឹងណា តើពូមានបានឃើញទិដ្ឋភាពទៀតក្រៅពី ការយាម ឬក៏អីហ្នឹងបាទ?

ផលៈ ដឹងឃើញទិដ្ឋភាពស្អី បើគេឲ្យយាមតែប៉ុណ្ណឹង ។

ខស្នានៈ ចុះលោកពូដែលឃើញអ្នកធំៗចូលទៅមើលនៅស-២១ហ្នុងទេ?

ផលៈ ឃើញៗ គេដើរអីចឹងទៅ ២,៣ថ្ងៃអីចឹងឃើញគេដើរម្តងកាត់អីចឹង ។

ខស្នានៈ ពីណាអ្នកធំហ្នុង?

ផលៈ ដើរមានណា មានតែបងប៉េងអីហ្នុង គាត់ដើរអីចឹងទៅ ប៉ុនដើរអីចឹងទៅគេសួរយើង អីចឹងទៅ គេសួរថាម៉េចអីដែរអីចឹងទៅ គេទៅវិញបាត់ទៅ ។

ខស្នានៈ ចុះអ្នកធំៗដូចមេខ្មែរក្រហមធំៗដែលចូលទៅទេ?

ផលៈ អត់មានទេ! តែត្រឹមថ្នាក់មន្ទីរទេ ធ្វើធំៗអត់មានដែលឃើញ អាហ្នឹងគេមកជួបគ្នាគេ ធំៗហ្នឹងណា ។

ខស្នានៈ ដែលដឹងទេ ពូដែលដឹងអីទេ ដែលដឹងថាមានអ្នកធំៗណាមកទេ?

ផលៈ អត់! បើមកកន្លែងធ្វើការបែបមាន ប៉ុនគេជួបគ្នាទៀតតាមកន្លែងបើកប្រជុំអីការងារ គេហ្នុងទៅណា រឿងដែលមកជួបជាមួយយើងជួបអីជួបតែគណៈមន្ទីរ គណៈអីហ្នឹង ហើយ ។

សុជាៈ ហើបង ក្នុងពេលបងយាមនៅទួលស្លែងហ្នុងបងមានដែលបានឮសេចក្តីប្រកាស ឬក៏ លិខិតអីថ្លែងការណ៍អីរបស់ថ្នាក់ដឹកនាំ ប៉ុល ពត ធំៗនៅសម័យហ្នុងទេ?

ផលៈ ហ្នុងឲ្យកាសែតយើងមើលអីចឹងដែរ ប៉ុនកាសែតមានន័យខុសគ្នាណា?

ដារ៉ាៈ មានន័យម៉េច?

ផលៈ  សម័យហ្នឹងវាមានតែទស្សនាវដ្ដីអីចឹងទៅណា ។

សុជាៈ  បាទ!

ផលៈ  យើងមើលទស្សនាវដ្ដីអីទៅ ទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យអីចឹងទៅ ។

ខស្មានៈ គេដាក់អីចឹង?

ផលៈ  បាទ! ហីយើងអីចឹងទៅ យើងមើលយើងដឹងដែរ ពាក្យស្លោកមួយគេលើក គេថាដូចឧបមាថា ខ្ញុំពីឆ្នាំប៉ុន្មានទេ ខ្ញុំភ័យជិតស្លាប់ហើយ ខ្ញុំភ័យខ្ញុំខ្លាចរើប្រវត្តិរូបដូចគាត់ ដែលគាត់យកមកថ្ងៃមុននោះ ប្រវត្តិរូបមកយកថ្ងៃមុននេះខ្ញុំខ្លាចអារឿងបើខ្ញុំលាក់គេខ្ញុំត្រូវមានទោសទៀត ប៉ុន្តខ្ញុំឆ្លើយខ្ញុំលាក់បងប្អូន២នាក់ ។

ខស្មានៈ ម៉េច និយាយថាយ៉ាងម៉េច?

ផលៈ  បងប្អូនខ្ញុំ២នាក់ជាប់និន្នាការដល់ខ្ញុំឆ្លើយទៅ គេត្រូវចាប់ខ្ញុំដាក់គុកដែរ ម្លោះហើយខ្ញុំលាក់បងប្អូន២នាក់ ហើយប៉ុនមកដល់ឃុំ ស្រុកគេដាក់ឲ្យតែ៦នាក់ហ្នឹងទៅវាត្រូវគ្នាទៅបានខ្ញុំរស់រាល់ថ្ងៃហ្នឹងណា ។

ខស្មានៈ ដាក់៦នាក់ម៉េច ខ្ញុំអត់ទាន់យល់ បងប្អូនបងទាំងអស់ប៉ុន្មាននាក់?

ផលៈ  បងប្អូនទាំងអស់ ម្ដាយខុសគ្នា ប៉ុន្តឪពុកជាមួយគ្នាណា ។

សុជាៈ  ហើយបងប្អូន២នាក់ហ្នឹងគាត់ជាប់និន្នាការអីគេ?

ផលៈ  ជាប់និន្នាការសម័យលន់ នល់ នោះ ។

សុជាៈ  ហើយបងប្អូន២នាក់ហ្នឹងមិនមែនឪតែមួយជាមួយគ្នាទេ?

ផលៈ  ឪជាមួយគ្នាម្ដាយខុសគ្នា ។

សុជាៈ  ហើយដល់ពេល៦នាក់នោះ?

ផលៈ  ៦នាក់ម៉ែតែមួយឪតែមួយ ។

សុជាៈ  ដល់ពេលប្រវត្តិរូបផ្ញើនៅស្រុកណោះ?

ផលៈ  ស្រុកហ្នឹងមកដល់គេសរសេរទៅវាត្រូវគ្នាខ្ញុំបានរួចខ្លួន ខ្ញុំថាអូ! ផ្ញើៗហ្នឹងខ្ញុំថាស្លាប់ហើយ ហើយលាក់ប្រវត្តិរូបកាលហ្នឹងក៏មានជាប់ដែរអីចឹង ។

ខស្មានៈ ឈ្មោះអីអ្នកដែលលាក់ប្រវត្តិរូបហើយជាប់គុក?

ផលៈ  ខ្ញុំភ្លេចបាត់ហើយ ប៉ុន្តែឃើញតែជាប់អីចឹង ។

ខស្មានៈ ឃើញជាប់មែន?

ផលៈ បាទ! ហ៊ីខ្ញុំបើខ្ញុំលាក់ប្រវត្តិរូបដូចថាពិនិត្យបងប្អូនជាប់និន្នាការពីហ្នឹងពីចឹងទៅ បើយើង ដាក់អីហ្នុងថាអត់ មើលតែស្រាវជ្រាវដឹងថាជាប់ទៅដល់ហ្នុងយើងមានទោសម៉ង។

សុជាៈ អីចឹងពូបាននិយាយម៉េចថាពូភ័យខ្លាចហ្នឹង នៅពេលដែលមើលទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យហ្នឹងប្ដុ?

ផលៈ អាហ្នឹងមើលកម្ពុជាប្រជាធិបតេយ្យហ្នឹង មើលបានន័យថា ហើយត្រង់ហ្នឹងវាមិនទាន់ មានការភ័យប៉ុន្មានទេអានេះគេនិយាយពីរឿងការងារប្រទេសគេទេណា ឯកសារ និយាយពីរឿងក្នុងឯកសារ ដូចថាគេមើលពាក្យមួយគេថាដឹកស្មៅដឹកឲ្យអស់ទាំងឫស នោះណាហ្នឹងមួយ បានន័យថាត្រូវចាប់ខ្ញុំមួយហើយត្រូវចាប់ទាំងអស់ម៉ារាជហ្នឹង។

សុជាៈ អាហ្នឹងនៅក្នុងទស្សនាវដ្ដី?

ផលៈ អត់ទេនៅក្នុងឯកសារយើងតូចទេ ឯកសារដូចថាសៀវភៅយើងប៉ុណ្ណឹងអីហ្នឹងណា។

សុជាៈ អីចឹងពូ! ទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យហ្នឹង គោលការណ៍គេ គេនិយាយពីស្អីខ្លះពូ នៅក្នុងសម័យនោះ?

ផលៈ និយាយពីរឿងរបបសង្គមនិយមហ្នុង។

សុជាៈ ហើយពូអានបានច្រើនដងទេ?

ផលៈ អានបានច្រើនដែរ ប៉ុន្តែវាភ្លេចអស់ហើយឥឡូវ កាលណុះដូចគាត់មកឲ្យអីចឹងខ្ញុំចេះ តែអានម្ដង២ដងអីចឹងទៅ ចាំបានខ្លះអីខ្លះអីចឹងទៅណា។

សុជាៈ ពូមានចាំទេអត្ថន័យនៃការសរសេររបស់គេហ្នឹងគេសរសេរអីខ្លះ?

ផលៈ ហ្អូ! ខ្ញុំចាំហ្នឹង ចាំតែម៉ាពេលមើលដឹងថាកម្ពុជាប្រជាធិបតេយ្យអីចឹងហើយ ប៉ុនថា ដល់ទៅច្រើនពេកទៅភ្លេចអស់អាដែល។

ដារ៉ាៈ អីចឹងបងខ្ញុំសុំសួរមួយបងទាក់ទងនិងពាក្យស្លោកមិញដែលថាបងធ្លាប់ចងចាំមាននៅក្នុង ទស្សនាវដ្ដីខ្មែរក្រហមហ្នឹងណា ពាក្យស្លោកថា ដឹកស្មៅដឹកទាំងឫសនឹងណា កាលហ្នុង មានន័យថាម៉េចបង?

ផលៈ មានន័យថា បើគេចាប់គ្រួសារណាគេចាប់ទាំងអស់ម៉ង គេចាប់រកមើលចាប់ទាល់តែ អស់ម៉ង ដាច់ម៉ាពូជៗម៉ង។

សុជាៈ អីចុងអាសម័យហ្នុងនៅក្នុងទស្សនាវដ្ដី ពូដែលឃើញថ្នាក់ដឹកនាំខ្មែរក្រហមអីចុះផ្សាយ ក្នុងទស្សនាវដ្ដីអត់?

ផលៈ ឃើញតែតាមរូបថត។

សុជាៈ ឃើញពីណាគេខ្លះបង?

ផលៈ ឃើញរូបប៉ុល ពតអីហ្នឹង ។

សុជាៈ រូបប៉ុល ពត ហ្នឹង?

ផលៈ នៅតាមទស្សនាវដ្ដីយើងផ្សេង អានេះផ្សេងទស្សនាវដ្ដី... ។

សុជាៈ ហើប៉ុល ពត ហ្នឹងគាត់ដែលសរសេរសេចក្ដីថ្លែងការណ៍នៅលើទំព័រកាសែតហ្នឹងទេ?

ផលៈ មានដែលមិនដឹង អត់មិនដឹងទេ បើខ្ញុំមើលវាភ្លេចអស់ទៅហើយ ។

សុជាៈ តែពូនិយាយមុនថាអត្ថន័យនៅក្នុងទស្សនាវដ្ដីហ្នឹង គេច្រើនតែអប់រំយើងឲ្យពីសម័យអីគេ?

ផលៈ ពីសម័យរបបហ្នុង អប់រំគឺថាគេឲ្យយើងកសាងខ្លួន កសាងអីចឹងទៅណា ។

សុជាៈ អត់មាននិយាយពីគោលនយោបាយថ្នាក់ដឹកនាំអីទេ?

ផលៈ គោលនយោបាយគេនិយាយពីបក្សកុម្មុយនីស្ដ បក្សអីអីចឹងទៅ ។

សុជាៈ អត់មានឲ្យប្រឆាំងនឹងវណ្ណៈ...?

ផលៈ អត់ឲ្យមានប្រឆាំងនឹងរបបកុម្មុយនិស្ដគេបានទេ គឺថាមានបក្សតែមួយ មើលក្នុងទស្សនាវដ្ដីហ្នឹងណា ។

ដារ៉ាៈ បង! បងថាពាក្យស្លោកមិញដែលបងថាជីកស្មៅជីកទាំងឫសហ្នឹងបង តើអាហ្នឹងអ្នកដែលអានណា ដូចថាដូចបងដូចខ្មែរក្រហមអីផ្សេងទៀតអានទៅ តើពាក្យស្លោកហ្នឹងវាអាចជាបញ្ហាឲ្យបងធ្វើអីចឹង ឬក៏យ៉ាងម៉េច?

ផលៈ អារឿងបទបញ្ជានៅរឿងគេថ្នាក់លើទេ ប៉ុន្តែយើងមានការព្រួយភ័យ ។

ដារ៉ាៈ អត់ទេនៅពេលតែបងអានពាក្យស្លោកហ្នឹងណា តើបងយលថាអាហ្នឹងជាកត្តាមួយជំរុញឲ្យខ្មែរក្រហមធ្វើ...?

ផលៈ គឺជំរុញឲ្យធ្វើ អាពាក្យស្លោកហ្នឹងគឺជំរុញឲ្យធ្វើម៉ង ប៉ុន្តែយើងវាគេចជាតិយើងមិនផុត ។

ដារ៉ាៈ អីចឹងនៅពេលដែលបងអានពាក្យស្លោកហ្នឹង បងគិតថាហ្នឹងវាជំរុញឲ្យបងធ្វើអីចឹង?

ផលៈ ហ្នឹងហើយ ជំរុញឲ្យធ្វើ ប៉ុន្តែបើយើងចង់គេចដែរ ចង់ថាមិនធ្វើក៏អត់ធ្វើបានដែរ ត្រូវតែធ្វើ ។

ដារ៉ាៈ បើថាចាប់ៗទាំងអស់ម៉ង?

ផលៈ ចាប់ទាំងអស់ម៉ង ។

ដារ៉ាៈ ជីកស្មៅ ជីកទាំងឫស?

ផលៈ បាទ! គេថាដីកស្មៅដីកឲ្យអស់ទាំងឫស អាហ្នឹងបានន័យថាគេចាប់តែមួយ គេត្រូវស្រាវជ្រាវទាំងអស់ ប៉ុន្តែយូហើឆាប់ដូចខ្ញុំដូចអី អីចឹង បើខ្ញុំខុសអីចឹង ទៅតែតាមហ្នឹងហើយ ។

ដារ៉ាៈ អាហ្នឹងមិនមែនជាការបញ្ហាទេ បងយល់ថាយ៉ាងម៉េចពាក្យស្លោកហ្នឹង?

ផលៈ ការបញ្ហាយើងគ្រាន់តែមើលទៅយើងឃើញថាអីចឹង ប៉ុន្តែយើងហ្នឹងយើងដឹងថាពីណាមានទោសមួយវាអាចគ្រោះថ្នាក់អស់មួយពូជហើយ បើសិនជាយើងមានគ្រោះថ្នាក់ម្នាក់ហើយណា បងប្អូនប៉ុន្មានសន្មត់ថាគេចាប់ទាំងអស់អីចឹងម៉ង ។

សុជាៈ អីចឹងអាហ្នឹងវាមិនមែនជាក្រិត្យដ្ឋវការអីចេញពី...?

ផលៈ អត់ទេអានេះអត់មាន អាបទបញ្ជាពីលើហ្នុងមកបានដាក់មកយើងបានឃើញ ។

សុជាៈ ដាក់បានឃើញអីចឹងនៅក្នុងលិខិតបទបញ្ជាគេហ្នឹង?

ផលៈ បទបញ្ជាក្នុងឯកសារគេ សៀវភៅគេ ប៉ុនៗហ្នឹង ។

ខស្មានៈ ហីនៅក្នុងសម័យហ្នុងដែលពូនៅក្នុងគុកទួលស្លែងហ្នុងពូ ពូមានដែលបានរៀនសូត្រអីអប់រំផ្នែកនយោបាយអី?

ផលៈ អប់រំផ្នែកនយោបាយមានអាការគេបន្ទិតបន្ទំឲ្យយើងធ្វើ ប៉ុនសម័យនោះយើងថាគេអប់រំណា ប៉ុនមកដល់សម័យបច្ចុប្បន្នគេថាវាការបន្ទិតបន្ទំឲ្យ យើងធ្វើទាំងអស់ហ្នុងហើយ ។

សុជាៈ អត់ទេ! មានដែលចូលរួមអង្គប្រជុំអី?

ផលៈ ប្រជុំធំ?

សុជាៈ បាទ!

ផលៈ អត់! អត់ទេ អត់ដែលបានទៅរៀន... ។

ខស្មានៈ រៀនវគ្គ រៀនអីហ្នឹងណា?

ផលៈ អត់ទេ! បានតែប្រជុំអាត្រឹមកន្លែងក្នុងមន្ទីរហ្នឹងណា ។

សុជាៈ បានតែក្នុងមន្ទីរហ្នឹង?

ផលៈ បាទ! បានតែប៉ុណ្ណឹងទេ បានគេប្រជុំអីចឹងទៅ ពាក់ព័ន្ធអីចឹងទៅណា ។

សុជាៈ បាទ! ៗមួយពីណាគេ?

ផលៈ ជាមួយប្រធានដូចខ្ញុំបាននិយាយមិញ ជាមួយបងហ៊ាជាមួយអីតែប៉ុណ្ណឹង ។

សុជាៈ គេនិយាយពីស្អីខ្លះពេលប្រជុំហ្នឹង?

ផល៖ ពេលលើករឿងរបបកម្ពុជាប្រជាធិបតេយ្យ ។

សុជា៖ របបហ្នឹងយ៉ាងម៉េច?

ផល៖ ហ៊ឺយ! ខ្ញុំចាំមិនអស់ទេ សើច...។

ដារ៉ា៖ អីចឹងបងពេលបងទទួល ដូចថាបានអានពាក្យស្លោកអីចឹង ចំពោះពាក្យស្លោកហ្នុង បងយល់ថាយ៉ាងម៉េច?

ផល៖ យល់ថារឿងគេចាប់កស្តុតាងបានមួយហ្នុងគេចាប់ទាំងអស់ម៉ង គេចាប់យកស្រាវជ្រាវតាមខ្សែរយៈ.......អស់តាស្បែក....

## កាសែ្សតទី២

ដារ៉ា៖ ចុះវ៉ាឌ្យូអីបងដែលបានស្តាប់ទេ?

ផល៖ វ៉ាឌ្យូក៏អត់ដែរសម័យហ្នុង ។

ដារ៉ា៖ អីចឹងមានតែទស្សនាវដ្តីហ្នឹងទេអីចឹង?

ផល៖ ហ្នឹងហើយ! ទាលលតែគេបើកឲ្យមើល វ៉ាឌ្យូបានស្តាប់ដែរ ប៉ុន្តែដូចថាយើង គេមិនមែនបើកឲ្យប្រើណា សម័យហ្នុងវ៉ាឌ្យូអ្នកណាបើកឲ្យប្រើគ្មានទេ ខ្ញុំនិយាយអីចឹង ខ្ញុំថាមានតែកន្លែងស៊ីបាយមួយទេ តាមផ្ទះតាមបុគ្គលយើងអីចឹងអត់មានទេ សម័យហ្នុងនោះ?

ដារ៉ា៖ ហើយអីចឹងសម័យហ្នុងវ៉ាឌ្យូគេអត់ឲ្យផ្សាយពីរឿងអីទេ?

ផល៖ ផ្សាយពីរឿងរបបកម្ពុជាប្រជាធិបតេយ្យបក្សកុម្មុយនីស្ត គេដឹកនាំឆ្ពោះទៅឈានទៅខាងប្រជាធិបតេយ្យហ្នុងណា គេអបរំប៉ុណ្ណុង...។

ដារ៉ា៖ ចុះមានដែលផ្សព្វផ្សាយពីគោលនយោបាយដឹកនាំប្រទេសអីយ៉ាងម៉េចៗទេ?

ផល៖ អត់ចាំទេ! ដឹងទេផ្សាយថាម៉េចទេ វាភ្លេចអស់បាត់ហើយ ចាំវាមិនអស់ទេ ។

ឧស្មានៈ ចុះពូពីការងារយាមហ្នុងលោកពូដែលធ្វើរបាយការណ៍ ឬក៏រាយការណ៍ទៅពីណាទេ?

ផល៖ អត់ដែលរាយការណ៍អីទេ ។

ឧស្មានៈ ឧបមាថាយាមប៉ះមានបញ្ហាអីមួយអីចឹងណាដែរទេ? ដែលរាយការណ៍ទៅពីណាទេ?

ផល៖ រាយការណ៍ទៅប្រធានក្រុមប្រធានអីហ្នឹងនោះ ។

ឧស្មានៈ ហើប្រធានក្រុមហ្នុងរាយការណ៍ទៅពីណាទៀត?

ផលៈ  រាយតាមខ្សែតាមថ្នាក់គេទៅលើៗទៀត ។

ឧស្មានៈ ថ្នាក់លើប្រធានក្រុមហ្នុងពីណា?

ផលៈ  ប្រធានក្រុមហ្នឹងដូចខ្ញុំនិយាយអីចឹងមុនដំបូងដូចថា ឈ្មោះគន ហ្នុងទៅ ដល់អាណត្តិគេចាត់ ដល់អាណត្តិដែលផុតអីចឹងគេចាប់គាត់បាត់អីចឹងទៅ គេដាក់មួយទៀតហ្នឹងមក ។

ឧស្មានៈ មួយទៀតហ្នុងឈ្មោះអី?

ផលៈ  មួយទៀតឈ្មោះថេត អីចឹងទៅ គេចាប់គាត់អីចឹងបាត់ទៀតទៅ ។

សុជាៈ  អីចឹងពូនៅក្នុងសម័យហ្នឹង ពូមានដែលទាក់ទងមកភូមិទេ?

ផលៈ  អត់រលីញ បាត់ម៉ែឪឈឹង ។

សុជាៈ  គេមិនឲ្យទាក់ទងមក ឬក៏យើងមិនបានទាក់ទងមក?

ផលៈ  គេមិនឲ្យយើងមកតែម្តង យើងអត់មានពេលដើរមក ។

សុជាៈ  គេបញ្ជាថាមិនឲ្យមកអីចឹង?

ផលៈ  យើងសុំគេក៏គេអត់ឲ្យមកដែរ ។

សុជាៈ  ចុះអត់មានបានទទួលដំណឹងពីណោះទៅវិញអត់?

ផលៈ  ដំណឹងទើបថ្ងៃដែលធ្វើប្រវត្តិរូបទេដឹងថាមែឪ ។

សុជាៈ  ថ្ងៃធ្វើប្រវត្តិរូបនៅណា?

ផលៈ  ថ្ងៃធ្វើប្រវត្តិរូបពីហ្នុងមកដែងស៊ីញ៉ោំងហ្នឹងណា មកផ្តិតមេដៃហ្នឹងទៀតបានដឹង ។

សុជាៈ  ដឹងថាម៉េចដែរ?

ផលៈ  ដឹងថាម្តាយនៅរស់ បងប្អូនមានប៉ុណ្ណេះៗអត់មានគ្រោះថ្នាក់អីណា ។

ដារ៉ាៈ  កាលនៅសាលាយោធា៧០៣ ណាបង នៅហ្នឹងគេបង្រៀនបងស្អីខ្លះ?

ផលៈ  គេរៀនពីរឿងក្បួនយោធា ក្បាច់បច្ចេកទេសតាមទម្លាប់របស់គេណា ការលូនលត់ក្រាប អារឿងបច្ចេកទេស អារឿងទ័ពទេណា មានរៀនតែប៉ុណ្ណឹងហើយ ហើនិងធ្វើស្រែប្រាំង ។

ដារ៉ាៈ  ហើចុះពេលដែលនៅសាលារៀនហ្នុងពេលដែលអ្នកបង្រៀន ឬក៏គ្រប់គ្រងនៅកន្លែងសាលាហ្នឹងណាឲ្យបងធ្វើអីមួយៗទៅ គេបញ្ជាតាមរបៀបម៉េច?

ផលៈ  គេចាត់តាំងពីលើមក គេចាត់តាំងពីថ្នាក់លើមកក្រុមចាត់តាំងយើងទៀតទៅថាឲ្យទៅបាច់ស្មៅដាំអាដែងស្ទូងស្រូវ យើងទៅ....

ដារ៉ា៖ អីចឹងអ្នកដែលប្រាប់បងផ្ទាល់ដែលថាទៅបោចស្មៅទៅបោចអីហ្នុង ត្រឹមក្រុមទេ?

ផល៖ បាទ!

ដារ៉ា៖ ហើក្រុមហ្នឹងបានពីណាមកទៀតបញ្ជាមក?

ផល៖ ពីលើទៀតមេគេ ។

ដារ៉ា៖ មេបងសំដៅត្រឹមណាបង?

ផល៖ បាទ!

ដារ៉ា៖ មេហ្នឹងបងសំដៅត្រឹមណា សំដៅត្រឹមថ្នាក់ណា?

ផល៖ ថ្នាក់ត្រឹមប្រធានលើ ប្រធានលើប្រធានសាលាគេម៉ង ប្រធានសាលាគេហ្នុងវាមាន ២, ៣នាក់ណុះ ប៉ុន្តែខ្ញុំភ្លេចអស់ហើយ ។

ខុស្នាន៖ អត់ចាំឈ្មោះខ្លះទេ?

ផល៖ ចាំបានតែ......(ភ្លែព្រុស) ....

ខុស្នាន៖ ឈ្មោះអី?

ផល៖ ភ្លែព្រុស......

ខុស្នាន៖ ទី ហ្នុងក្រោយមកមានមកនៅស-២១ទេ ទទួលបន្ទុលសាលាហ្នុង?

ផល៖ អត់ដែរឮ ។

ខុស្នាន៖ ហើពូដែលដូចមានបញ្ហាដូចអ្នកទោសអីរត់ចេញពីកន្លែងហ្នុងមានទេ?

ផល៖ អត់ទេ!

ខុស្នាន៖ មានអ្នកទោសដែលលួចរត់លួចអីទេ?

ផល៖ អត់ទេ!

ខុស្នាន៖ ហើយដែលគេដោះលែងទេ?

ផល៖ គេដោះលែងម៉េច?

ខុស្នាន៖ ដោះលែងឲ្យរួចខ្លួន?

ផល៖ ដោះទៅឃើញតែគេបញ្ជូនមកបាត់ៗម៉ង ហើយយើងវាអត់ដឹងអារឿងបញ្ហាហ្នឹងដែរ គេថាឲ្យមកអគ្គភាពៗហ្នុងមកបាត់មកអាហ្នឹងខ្ញុំនិយាយទេប៉ុណ្ណឹងទេ ។

ខុស្នាន៖ ចុះលោកពូដែលថតរូបទេ?

ផល៖ រូបថតខ្ញុំហ្នឹងមាន ។

ខុស្នាន៖ ថតប៉ុន្មានដង?

ផល៖ ថតម្ដង ។

ខស្នាន៖ កាលលោកពូនៅឯណា?

ផល៖ នៅហ្នឹងម៉ង ។

ខស្នាន៖ នៅស-២១?

ផល៖ បាទ!

ខស្នាន៖ រូបថតហ្នឹងដឹងលោកពូគេយកទៅណា គេប្រាប់ថាម៉េច?

ផល៖ ថតហ្នឹងគេថាថតធ្វើកាត ។

ខស្នាន៖ ហើយដែលបានបណ្ណ័សំគាល់ខ្លួនទេ?

ផល៖ អត់មានបានទេ!

ដារ៉ា៖ បងខ្ញុំសុំសួរបញ្ជាក់កន្លែងនេះបង នៅពេលបងធ្វើការអីមួយបង បងបាន អ្នកណាប្រាប់ឲ្យបងធ្វើកាត ចង់និយាយថាបងទទួលបញ្ជាហ្នឹងពីណាមកទម្រាំបងបានការងារមួយដែលបងទៅធ្វើណា បងយល់ទេ?

ផល៖ ហ្នឹងគេចាត់តាំងតាមខ្សែរយៈមកយើងអត់ដឹងដែរ ដឹងពីណាចាត់តាំង ចេះតែមកតាមខ្សែបណ្ដាញមក ការងារមួយអីចឹងគេដាក់ដូចខ្ញុំបាននិយាយហើយណា កាលមុនខ្ញុំកន្លែងសាលាយោធា ដល់ក្រោយមកបញ្ជូនមកណេះមក ដល់ក្រោយមកទៀតមកនៅព្រៃសរចេះតែមកហ្នឹងមកធ្វើការហ្នឹងគេហ្នឹងម៉ង ដឹងពីណាគេពូតម្កុំការងារថាឲ្យខ្ញុំបានធ្វើនោះ ។

ដារ៉ា៖ នៅកន្លែងស-២១ពេលដែលខ្ញុំយាមអ្នកទោសហ្នឹង កិច្ចការដែលយាមហ្នឹងបងទទួលការណែនាំពីខាងណា?

ផល៖ ទទួលការណែនាំពីប្រធានក្រុមប្រធានក្រុមប្រធានមន្ទីរ ។

ដារ៉ា៖ បងទទួលបីត្រឹមប្រធានក្រុម ឬក៏ធ្លាប់ទទួលពីប្រធានមន្ទីរ?

ផល៖ ទទួលតែពីត្រឹមក្រុម ប្រធានមន្ទីរយូៗ ទើបកាលប្រជុំតែម្ដងទេ ។

ដារ៉ា៖ គាត់ដែលប្រជុំដែល?

ផល៖ ហ្នឹងហើយប្រជុំម្ដងទេ ក្រៅពីនេះហ្នឹងដែនការចាត់ទៅតាមក្រុមមក ។

ដារ៉ា៖ នៅពេលដែលប្រជុំហ្នឹងចូលទាំងសមាជិកក្រុម ឬក៏ប្រជុំតេប្រធានក្រុមទេ?

ផល៖ គេប្រជុំប្រធានក្រុម ជួនកាលអីចឹងទៅគេយកទាំងអស់ទៅប្រជុំម្ដងអីចឹងទៅណា ។

ដារ៉ាៈ ប៉ុន្តែមិនមែនបានន័យថាឲ្យតែប្រជុំខាងមន្ទីរស-២១ប្រធានៗហ្នឹងគេហៅតែប្រធានក្រុមទេឬ?

ផលៈ ប្រធានក្រុម ជួនកាលគេហៅតែប្រធានទេ យើងមានដឹងអី អត់ដឹងផង ។

ដារ៉ាៈ តែបងធ្លាប់ចូលប្រជុំ....?

ផលៈ ខ្ញុំចូលប្រជុំបានតែម្តងទេ ។

ដារ៉ាៈ ជាមួយប្រធានមន្ទីរឬ?

ផលៈ បាទ! ចូលហ្នុងចូលរួមគ្នាទាំងអស់ គេថាដូចគេធ្វើមីទ្ទិញអីគេនោះណា... ។

ដារ៉ាៈ ហើក្នុងប្រជុំហ្នុងគេច្រើននិយាយពីស្អីបង.?

ផលៈ គេនិយាយពីរឿងរបបគេហ្នុង ។

ដារ៉ាៈ របប ឬក៏ការងារនៅក្នុងកន្លែងហ្នឹង?

ផលៈ បាទ! ការងារយើងហ្នឹង ជួនកាលគេបំផុសពីការងារហ្នឹង ជួនកាលគេបំផុសអារឿងការងារ....អីចឹងទៅ ប៉ុនខ្ញុំមិនបានចាំអស់ទេ ចាំបានតែគោលៗ ។

ដារ៉ាៈ អីចឹងរាល់កិច្ចការដែលបងធ្វើហ្នឹងសុទ្ធតែ បងធ្វើមានការណែនាំ ឬក៏ជួនកាលបងអាចអាកាត់អីសម្រេចខ្លួនឯងបានដែរ?

ផលៈ អត់ទេ! អត់មាន មិនដឹងអាកាត់ទៅត្រង់ណារួច បើនៅហ្នឹងគេ គេគាបជាប់ ។

ខស្នានៈ បងនៅកន្លែងហ្នុងរហូតដល់ពេលណា?

ផលៈ ខ្ញុំនៅ?

ខស្នានៈ បាទ!

ផលៈ ខ្ញុំនៅពីឆ្នាំដើមឆ្នាំ៧៧ ។

ខស្នានៈ ហើរហូតមកដល់ពេលណា?

ផលៈ ខ្ញុំនៅដល់៧៧ជាង ដាច់ចូល៧៨ ខ្ញុំសម្រាកការងារ ខ្ញុំដូចគេនៅវ័យក្មេងគេបញ្ជូនមកឲ្យធ្វើស្រែវិញ ។

ខស្នានៈ អូ! ពាក់កណ្តាល៧៨ ឬក៏ដើម៧៨?

ផលៈ ពាក់កណ្តាល អើ៧៧យើងចូលណា ដាច់៧៧ចូល៧៨ប្រហែលបានកន្លះខែ ម៉ាខែ អាហ្នឹងគេឲ្យខ្ញុំមកវិញ គេឲ្យបញ្ជូនមកធ្វើស្រែវិញ កងកុមារហ្នឹងណា ។

ខស្នានៈ ធ្វើស្រែនៅណា?

ផលៈ ធ្វើស្រែនៅព្រែកហូរដដែល ។

ខស្មានៈ មកនៅព្រែកហូរវិញទៀត?

ផលៈ បាទ! មកនៅព្រែកហូរទៀត ។

ខស្មានៈ ម៉េចបានអីចឹងពូ?

ផលៈ ម៉េចអីចឹង ដឹងអាម៉េចបើគេបញ្ជូនឲ្យនៅហ្នឹង ។

ខស្មានៈ គេថាយ៉ាងម៉េច?

ផលៈ គេថាកុមារឈានមុខ គេថាអីចឹង ទៅចាំដល់ធំបន្តិចទៀតបានគេឲ្យកាន់ការងារហ្នឹង អាថាអីចេះណា យើងនៅក្មេង គេឲ្យមកនៅហ្នឹងវិញទេខ្ញុំនោះ ។

ខស្មានៈ ចុះម៉េចបានដឹបូងបានគេយកទៅ?

ផលៈ ថាម៉េចទេខ្ញុំវាអត់សួរដឹងដែរ គេចេះតែបញ្ជូនៗទៅ ចេះតែទៅហ្នឹងគេទៅណា ។

ខស្មានៈ ហើយចុះបន្ទាប់មកទៀតមានទៅចូលកន្លែងហ្នុងវិញទេ?

ផលៈ អត់ទេ! ខ្ញុំមកនៅហ្នឹង៧៨ ៧៩ហ្នឹងរត់បណ្តោយ ។

ខស្មានៈ រត់មកនៅឯណា?

ផលៈ ខ្ញុំរត់ទៅណុះអមលាំង ។

ខស្មានៈ ដល់អមលាំង?

ផលៈ បាទ! ដល់អមលាងរួចមកវៃយួន សម័យនោះមិនយួនមកណា មកវៃយួននៅត្រពាំងក្រឡឹងនេះទៀតបានរត់ម្តងទៀតនោះធ្លាក់ថៃណុះ ។

ខស្មានៈ ហើចុះពូចូលមកភូមិនេះឆ្នាំណា?

ផលៈ ចូលមកឆ្នាំ៧៩ ។

ខស្មានៈ ៧៩ ទោដល់ថៃណុះហើយ?

ផលៈ បាទ! ប៉ុនអត់បានចូលថៃទេ គ្រាន់តែក្បែៗជាយរបងអាណាហានចូលទៅគេ ។

ដារ៉ាៈ បងនៅក្នុងអង្គប្រជុំដែលបងធ្លាប់ចូលរួមប្រជុំនៅមន្ទីរស-២១ហ្នឹងណា បងមានដែលធ្លាប់ឮនៅក្នុងអង្គប្រជុំមាននិយាយពីរឿងវត្តអារាម ឬក៏ស្អីផ្សេងៗទេបង?

ផលៈ អត់! វត្តអារាមមន្ទីរស្អីៗគេអត់ដែលនិយាយផង គេនិយាយតែពីរឿងគេកសាងសង្គមគេម៉ង ។

ដារ៉ាៈ ហើចុះកាលឆ្នាំ៧៨អីចឹង ដែលបងនៅវត្តណា ហើយដែលមានការជម្លៀសពេលហ្នុងនោះ ចុះលោកសង្ឃត្រូវបានជម្លៀសដែរឬ?

ផលៈ បាទ! ជម្លៀសទៅទាំងអស់ ។

ដារ៉ាៈ ជម្លៀសទៅណា?

ផលៈ ទៅតានី ។

ដារ៉ាៈ ហើវត្តហ្នឹងគេទុកធ្វើអីទៅ?

ផលៈ វត្តហ្នឹងដឹង! បើយកលោកទៅអស់ហើយយើងដឹងថាគេទុកធ្វើអី លោកក៏ទៅប្រជាជនក៏ទៅអស់ ។

ដារ៉ាៈ ហេតុអីបានគេជម្លៀសលោកសង្ឃដែរ?

ផលៈ ដឹង! បើខ្ញុំអត់ដឹងដែរ បើគេជម្លៀសទៅអស់ ។

ប្រពន្ធៈ កាលហ្នុងគេខ្វាចយើងឲ្យ បញ្ចេញអង្ករបញ្ចេញអីឲ្យទាហានខាងក្នុងនោះណា... ។

ដារ៉ាៈ ទាហានខាងក្នុងទាហានណា?

ផលៈ ទាហានលន់ ណុលហ្នឹង ។

ប្រពន្ធៈ ដល់ខ្លាចយើងឲ្យយកយើងទៅឲ្យឆ្ងាយ កុំមកស្រួលគេធ្វើការ ។

សុជាៈ អីចឹងអ្នកជម្លៀសហ្នឹងទាហានខ្មែរក្រហមសម័យហ្នុង?

ប្រពន្ធៈ ចា៎!

ផលៈ ហើគ្រប់វត្តអារាមរុះទាំងអស់ ។

សុជាៈ គ្រប់វត្តអារាមទាំងអស់?

ផលៈ បាទ! ឲ្យតែនៅដីតំបន់រំដោះ ។

សុជាៈ ចុះពេលលោកគាត់ចេញពីវត្តហ្នឹងទៅ គាត់និមន្តចេញពីវត្តហ្នឹងទៅ គាត់នៅភាពជាសង្ឃឬក៏...?

ប្រពន្ធៈ សង្ឃ ប៉ុនដល់នេះសឹកអស់បាត់ហើយ ។

សុជាៈ គេផ្សឹកគាត់ ឬក៏គាត់ផ្សឹកខ្លួនឯង?

ផលៈ គេផ្សឹកណា ។

ប្រពន្ធៈ គេផ្សឹកខ្លះ សឹកខ្លួនឯងខ្លះ ។

ផលៈ គេឲ្យសឹក លោកខ្លះអត់សឹកទៅក៏អត់ទៅ ប៉ុននៅអត់អ្នកណាគាំទ្រត្រូវតែសឹកដែរ ចុះរាជហ្នុង ព្រះតេជគុណ ម៉ាន ព្រះចៅអធិការវត្ត មិនគេយកទៅសម្លាប់ចោលពួកជម្លៀសហ្នឹង ។

សុជាៈ ភូមិនេះកាលមុនមានវិហារត្រឹមត្រូវដែរកាលពីមុនសម័យ ប៉ុល ពត?

ផលៈ មាន!

សុជាៈ តែដល់ពេលហើយវត្តហឹងវាត្រូវម៉េចដែរ ក្រោយពីសម័យហ្នឹងមក?

ផលៈ ក្រោយពីសម័យណា?

សុជាៈ ក្រោយពីសម័យប៉ុល ពតហ្នឹងវត្តអារាមនៅឬក៏មានការរុះរើ?

ផលៈ ប៉ុល ពត ឬសម័យក្រោយអាពតរំដោះបាន?

សុជាៈ ក្រោយពីសម័យប៉ុល ពតមក៧៩មកបង?

ផលៈ អត់មានទេ! រើពីសម័យប៉ុល ពតអស់រលីញ ។

សុជាៈ អីចឹងវត្តហ្នឹងក្នុងសម័យប៉ុល ពតគេធ្វើអីដែរ?

ផលៈ ដីងគេរើយកទៅណា យកធ្វើជាទំនប់ទឹក ធ្វើជាស្អីអស់បាត់ហើយទេ ស្ពានអីអស់ហើយទេ ។

ដារ៉ាៈ អីចឹងវត្តហ្នឹងត្រូវបានរើដែរ?

ផលៈ ខ្ញុំ?

សុជាៈ អត់ទេ! ក្នុងសម័យប៉ុល ពតហ្នឹងវត្តអារាមហ្នឹងត្រូវបានគេរើដែរ?

ផលៈ គេរើសម័យប៉ុល ពតហ្នឹងរើ ។

ដារ៉ាៈ ម៉េចបងដឹង?

ផលៈ ចុះខ្ញុំមកឃើញអស់រលីញទៅហើយ កាលខ្ញុំទៅនៅចគ្រុង ហើយមកដល់ពួគេរុះរើអស់ឃើញអត់មានមែន អានេះទើបធ្វើថ្មី ។

ដារ៉ាៈ អីចឹងវត្តនៅកន្លែងនោះដដែលទេ?

ផលៈ នៅវត្តនោះដដែល ។

ដារ៉ាៈ គ្រាន់តែវិហារហ្នឹងធ្វើថ្មី?

ផលៈ វិហារទើបនឹងកសាងថ្មី ។

សុជាៈ មុនសម័យប៉ុល ពតហ្នឹងវត្តហឹងគេធ្វើឈើ ឬក៏ថ្មបង?

ផលៈ ឈើ ។

សុជាៈ ឈើ?

ផលៈ បាទ!

សុជាៈ ហឹដល់ពេលគេរើមក គេយកទៅធ្វើស្អីខ្លះទៅ?

ផលៈ យកទៅធ្វើស្ពានឆ្លងព្រែកឆ្លងអីចឹងទៅ ឆ្លងប្រឡាយអីចឹងទៅ ។

សុជាៈ ចុះដល់ពេលដីនៅក្នុងវត្តហ្នឹង វត្តអារាមហ្នឹងគេយកធ្វើអីទៅបង?

ផលៈ ដីដីងគេយកធ្វើស្អី ដីដូចអត់មានថាយកធ្វើស្អីផង គេយកធ្វើជានេះ គេធ្វើជាមន្ទីរពេទ្យ អាហ្នឹងតាមខ្ញុំមកវិញហើយណា ខ្ញុំសួរតាមគេ គេប្រាប់ថាយកធ្វើមន្ទីរពេទ្យ ។

ដាវ៉ាៈ ចុះពូពេលជម្លៀសពីវត្តណាពូ អ្នកណាមកជម្លៀស ពូមានស្គាល់ឈ្មោះអ្នកណាមួយ ឬក៏ប្រធានក្រុមណាមួយ?

ផលៈ អត់ទេ! ឮដូចថាគ្មានពីគេមកបង្ហាញខ្លួនឲ្យពេញមុខទេណា គ្រាន់តែថាគេជម្លៀសគេជម្លៀស ហើយ ក៏នាំគ្នាមួយទៅៗអស់ទៅទេ ។

ដាវ៉ាៈ អីចឹង?

ផលៈ បាទ!

ដាវ៉ាៈ អីចឹងមិនមែនមានន័យថាមានអ្នកមក...។

ផលៈ អារឿងគេមកអីចឹង គេមកប្រាប់តែគ្នាធំៗហើយណា ប្រាប់ដូចប្រធានភូមិប្រធានអី ប្រធានភូមិអីចឹងប្រាប់ម៉ែប្រាប់ឪខ្ញុំ ខ្ញុំអត់បាននៅដែរអាលេងតែទៅមើលគោមើល បាត់ទៅម៉ែឪ កាលហ្នុងខ្ញុំនៅវត្ត ហើយយើងខស្សាហ៍ទៅលេងផ្ទះដែរ ប៉ុនថាដល់ពេល អីចឹង គេមកឲ្យថយអីចឹង ក៏ដឹងតាមហ្នឹងដែរ ដឹងតាមដែនការឲ្យថយហ្នឹង មួយប្រាប់ មួយៗទៅបីភូមិមកក្រុមអីចឹងទៅ គេថយអស់ទៅណាខ្ញុំទៅអត់ទាន់គេទេ ។

ដាវ៉ាៈ កាលជំនាន់ហ្នុងប្រធានភូមិឈ្មោះអីគេ ពូចាំទេ?

ផលៈ ជំនាន់ប្រធានភូមិកាលហ្នុងឈ្មោះអីកាលហ្នុង?

ប្រពន្ធៈ ខ្ញុំអត់នៅដែរ ខ្ញុំចេញផុតដែរ ។

ផលៈ ប្រធានភូមិកាលហ្នុងឈ្មោះទេ ឈ្មោះណាគ អីមិនដឹង ។

ប្រពន្ធៈ ម៉ាស្រុករខ្ញុំអីអត់បាននៅផ្ទះទេ ចេញផុតអស់ហើយ ។

ផលៈ ប្រធានភូមិបណ្តោះអាសន្នឈ្មោះណាគ មិនដឹងឈ្មោះអីទេ ។

ដាវ៉ាៈ ឈ្មោះណាគ អីចឹងឬ?

ផលៈ ហ្នុងហើយ ។

ដាវ៉ាៈ ចុះឃុំ?

ផលៈ ឃុំអត់ដឹង ។

ដាវ៉ាៈ អត់ដឹងទេ?

ផលៈ សើច...ខ្ញុំអត់ដែរទៅណាឃុំ បើនៅតែហ្នឹងភូមិខ្ញុំដឹងខ្លះ...។

សុជា៖ អីចឹងពូកាលសម័យហ្នឹងកាលពូមកក្នុងភូមិវិញពូមានឃើញថាវត្តហ្នឹងត្រូវបានគេរុះរើចេញហើយណាពូន៎?

ផល៖ ហ្នឹងហើយ!

សុជា៖ ចុះសាលាពូ?

ផល៖ សាលានៅដដែល ។

សុជា៖ នៅដដែល! តែនៅក្នុងសម័យប៉ុល ពតហ្នឹងសាលារៀនត្រូវបានគេបង្រៀនក្មេងៗដែរឬអត់ទេ?

ផល៖ អត់ដឹង! ខ្ញុំអត់នៅហ្នឹងផង ។

ប្រពន្ធ៖ បង្រៀនក្មេងគេបង្រៀនតាមសាលានៅតាមភូមិ ។

ផល ខ្ញុំអត់ដឹងទេណា ដឹងគេរៀនហ្នឹងយ៉ាងម៉េចទេណា ។ ប៉ុន្តែខ្ញុំមកវិញក្រោយ៧៩ឃើញគេនៅណា បី៧៩មកនៅ ទើបនឹងរើធ្វើឥឡូវធ្វើថ្មីហ្នឹងណា ។

សុជា៖ ហីពូគិតថាម៉េចដែរ ពេលដែល ប៉ុល ពតរុះរើវត្តអារាមអីចឹង ពូគិតថាយ៉ាងម៉េច ដែរគោលនយោបាយរបស់ថ្នាក់លើរបស់ប៉ុល ពតហ្នឹង?

ផល៖ ខ្ញុំអត់ដឹងថាម៉េចដែរបើរាល់ថ្ងៃដឹងថាផ្សេង បើនិយាយម៉ារាជហ្នឹង ម៉ារាជសម័យប៉ុល ពតណា កាលហ្នឹងខ្ញុំអត់បានចាប់អារម្មណ៍អីទេ ។

សុជា៖ កាលហ្នឹងសម័យប៉ុល ពតហ្នឹងពូអត់ដឹងថាគេធ្វើអីខ្លះទេន៎?

ផល៖ អត់ដឹងគេធ្វើអីខ្លះទេ ប៉ុន្តែមកដល់ម៉ែបងប្អូនគេប្រាប់ថាវត្តយើងរើអស់ហើយ ។

ដារ៉ា៖ ពូអីចេះដែលខ្ញុំខស្សាហ៍សួរពូទាក់ទងនឹងការសួរឈ្មោះអ្នកដែលពូស្គាល់ ប្រធានកន្លែងមួយទៅកន្លែងមួយហ្នឹងពូ វាទាក់ទងថា បើពូអាចស្គាល់ពូជួយប្រាប់ឈ្មោះដែលប្រធានក្រុមប្រធានភូមិ ឬក៏ប្រធានកន្លែងដែលពូនៅមួយហ្នឹងអ្នកណាប្រធាន អ្នកណាក្រុមអ្នកណាអីហ្នឹងពូ ព្រោះភ្ជាប់ដូចថាខ្សែរយៈពីខាងក្រោមទៅខាងលើ ពីខាងលើមកខាងក្រោម ។

ផល៖ ដូចខ្ញុំបាននិយាយមនុស្សអត់ចាំទេ ភ្លេចអស់ហើយរឿងឈ្មោះនោះ ។

ដារ៉ា៖ អីចឹងនៅក្នុងម៉ាកំឡុងពេលពូ ដែលធ្វើការនៅទួលស្លែងពូមានធ្លាប់ឮអ្នកណានិយាយប្រាប់ ឬក៏ធ្លាប់ឃើញផ្ទាល់ភ្នែកអំពីការសម្លាប់មនុស្សទេពូ?

ផល៖ ឃើញខ្ញុំអត់បានឃើញ ។

ដារ៉ា៖ ចុះពូដែលធ្លាប់ឮគេនិយាយប្រាប់ទេ?

ផលៈ អត់!

សុជាៈ អីចឹងការសមាប់មនុស្សហ្នឹងពូដឹងក្រោយពេលដែលពូ...?

ផលៈ ហ្នឹងហើយ! ដឹងក្រោយ ។

សុជាៈ ចេញមកភូមិមកអីវិញហើយ?

ផលៈ ហ្នឹងហើយ!

ខស្នានៈ ពូខ្ញុំគិតថា ដូចថាអ៊ីៗដែលខ្ញុំបានសួរ ហើលោកពូក៏បានប្រាប់ខ្ញុំបានច្រើន ខ្ញុំអរគុណច្រើនមែនទែន បើសិនជាថ្ងៃក្រោយទៅ ប្រសិនជាខ្ញុំត្រូវការសួរចំណុចបន្តិចបន្តួចទៀត ក្រែងលោថាខ្ញុំយកទៅស្តាប់វាមានការចន្លោះខ្វះដែលមិនទាន់បានដឹងអស់ណា ហើយខ្ញុំអាចត្រឡប់មកជួបលោកពូទៀតបានទេលោកពូ បើសិនជាមានពេលណាខ្ញុំត្រឡប់មកវិញទៀត?

ផលៈ ខ្ញុំសារឿងចាំហ្នុងវាចាំតិចណាស់អារឿងសួរឈ្មោះរកអីគ្រប់កន្លែងគ្រប់ខណៈពេល អត់ទេភ្លេចច្រើនណាស់ នៅតែអត់ដដែលហ្នុង ។

ខស្នានៈ បើសិនជាថ្ងៃណាមួយខ្ញុំចង់មកលេងម្តងទៀត ចង់ជួបនិយាយលេង... ។

ផលៈ មានតែប៉ុណ្ណឹងក្មួយអើយ ខ្ញុំវាអស់ ដូចថាវាអស់ការនិយាយហើយ ។

ខស្នានៈ សើច... ។

សុជាៈ ប៉ុនពូនៅតែស្មាគមន៍ដែរឬ?

ផលៈ បាទ!

សុជាៈ ថ្ងៃក្រោយមកខ្ញុំមកអីចឹងពូនៅតែស្មាគមន៍ពួកខ្ញុំដដែលទេ?

ផលៈ ចុះមានស្អី ។

សុជា,ខស្នានៈ សើច......

ដារ៉ាៈ អរគុណពូច្រើនណា!

ផលៈ បាទ!

ចប់